ឯកសារការងារចុះមូលដ្ឋានស្តីពី

A FIELD MANUAL ON

# ការចូលរួមគ្រប់គ្រងសហគមន៍នេសាទ

# COMMUNITY FISHERIES MANAGEMENT



IDRC CANADA

Oxfam America

Oxfam GB

WWF

# ឯកសារការងារមូលដ្ឋានសំរាប់អ្នកសំរបសំរួល

## ស្តីពី

# ទស្សនៈទាន និងដំណើរការគ្រឹះ

# ក្នុងការគ្រប់គ្រងសហគមន៍នេសាទ

### ឧបត្ថម្ភដោយ

IDRC CANADA

Oxfam America

Oxfam GB

WWF

### រៀបចំដោយ


| | | |
|---|---|---|
| លោក | គីម ណុង | ប្រធានគំរោង PMMR, MoE/IDRC |
| លោក | និន វ៉ាន់ថា | ប្រធានក្រុមស្រាវជ្រាវគំរោង PMMR, MoE/IDRC |
| លោក | អ៊ុក លីឃីម | គំរោង PMMR, MoE/IDRC |
| លោក | ស៊ុម ប៊ុនធឿន | អង្គការ Oxfam America |
| លោកស្រី | ងិន ណារីរៈ | អង្គការ Oxfam Great Britain |
| លោកស្រី | សូ ស្រីមុំ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| លោក | ម៉ម កុសល | អង្គការដីសើមអន្តរជាតិ (WI) |
| លោក | លី វុទ្ធី | ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ |
| លោក | ទូច វីណា | ការិយាល័យដែនដី ក្រសួងបរិស្ថាន |
| លោក | តូប៊ី ខាសុន | ទីប្រឹក្សា CBNRM |


ឆ្នាំ ២០០២


ម.ព.ឯ.ក AIDOC
Code: 139-043
Date:
Donated by:

# អារម្ភកថា

គំរោងការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង ដែលមានការគាំទ្រដោយក្រសួងបរិស្ថាន និងការជួយឧបត្ថម្ភដោយមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា មានទិសដៅនិងគោលបំណងជំរុញអោយមានការចូលរួមការពារ និងគ្រប់គ្រងធនធានធម្មជាតិអោយមាននិរន្តភាព ។ អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានខិតខំចងក្រងឯកសារនេះឡើង ដើម្បីជាទុនសំរាប់អ្នកធ្វើការជាមួយសហគមន៍នៅតាមតំបន់នានានៃប្រទេសកម្ពុជា ដែលសព្វថ្ងៃយើងកំពុងមានការខ្វះខាតយ៉ាងខ្លាំងនូវរាល់ឯកសារនានាពិសេសលើការចូលរួមគ្រប់គ្រងសហគមន៍នេសាទ ។ យើងខ្ញុំសង្ឃឹមថា ឯកសារនេះនិងចូលរួមចំនែកលើកស្ទួយសេដ្ឋកិច្ចសង្គម និងតួនាទីអ្នកចូលរួមគ្រប់គ្រងធនធានធម្មជាតិអោយកាន់តែយល់ដឹងច្បាស់នូវរាល់យុទ្ធសាស្ត្រក្នុងការធ្វើផែនការគ្រប់គ្រងធនធាន និងគំនិតពិចារណាមុននឹងចាប់ផ្ដើមធ្វើអ្វីមួយ ។ ការចងក្រងឯកសារនេះមានការលំបាកខ្លះដែរ ដោយយើងខ្ញុំពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការកែសំរួលអោយបានល្អទាំងបច្ចេកទេស អក្ខរាវិរុទ្ធ និងរូបភាព ។ ក្រុមយើងខ្ញុំទទួលយកដោយក្ដីរីករាយ រាល់ការរិះគន់កែលំអពីសំណាក់អ្នកអាន និងអ្នកប្រើប្រាស់ទាំងអស់ ដើម្បីអោយការរៀបចំនៅពេលក្រោយកាន់តែមានភាពសុក្រិត និងល្អប្រសើរ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជូន លោក លោកស្រី ដែលប្រើប្រាស់សៀវភៅនេះ មានសុខភាពល្អ កំលាំងមាំមួន ប្រាជ្ញាភ្លឺថ្លា និងសំរេចបានជោគជ័យរាល់ភារកិច្ចរបស់ខ្លួន។

**ប្រធានគំរោង**

**គីម ណុច**

# សេចក្តីថ្លែងអំណរគុណ

ឯកសារការងារមូលដ្ឋាននេះត្រូវបានបង្កើតឡើងតាមរយៈនៃការយល់ដឹង និងចំណេះដឹងនៃប្រជានេសាទកម្ពុជា ដោយបានជួយជ្រោមជ្រែងដល់ក្រុមការងារតំរោង (ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង) រៀបចំឱ្យមានសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើននៅតាមតំបន់ឆ្នេរ និងនៅតាមតំបន់បឹងទន្លេសាប ដើម្បីសាកល្បងសកម្មភាពការងារផ្សេងៗកត់ត្រាចូលក្នុងឯកសារនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះប្រជានេសាទប្រធានភូមិ និងប្រធានឃុំ (រាម និងពាមក្រសោប) មន្ត្រីរដ្ឋាភិបាល (ជាពិសេសមន្ត្រីមកពីក្រសួងបរិស្ថាន និងនាយកដ្ឋានជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល (អង្គការមិត្តភាពអាមេរិកាំងនៅខេត្តកោះកុង) ទាំងអស់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពទាំងនេះ ។ ប្រសិនបើពុំមានការចូលរួមពីសំណាក់អស់លោកទេនោះ ឯកសារនេះនឹងមិនអាចចងក្រងឡើងបានដោយងាយនោះឡើយ ។

សមាជិកគណៈកម្មាធិការតម្រែតម្រង់ (សមាជិកអង្គការ Oxfam អាមេរិកាំង, Oxfam អង់គ្លេស, NGO Forum, WWF, អង្គការជីវិតអន្តរជាតិ, នាយកដ្ឋានជលផល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន) បានជួយកែសំរួលឯកសារស្តីពីសហគមន៍នេសាទនេះឱ្យមានភាពសមស្រប និងទៅតាមតំរូវការបច្ចុប្បន្ន ។ មិនតែប៉ុណ្ណោះពួកគេបានរៀបចំឯកសារនេះជាភាសាខ្មែរ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកសំរបសំរួលគណៈកម្មការសហគមន៍ ឬអ្នកប្រើប្រាស់ផ្សេងទៀតក្នុងគោលបំណងគ្រប់គ្រងសហគមន៍នេសាទ ។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោក Wayne Gum និង លោក Fermin Manalo Jr. ដែលបានបរិច្ចាគសំរាប់ការរៀបចំឯកសារនេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះមជ្ឈមណ្ឌល "គ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍" ក្នុងប្រទេសហ្វីលីពីន ដែលបានជួយឧបត្ថម្ភដល់ការផ្តួចផ្តើមសកម្មភាព

នេះ និងដែលបានជួយបន្តសំរបសំរួលក្នុងការផ្លាស់ប្តូរចំណេះដឹង និងទេពកោសល្យ រវាងអ្នកគ្រប់គ្រងធនធានតំបន់ឆ្នេរនៅក្នុងតំបន់អាស៊ី ។

សូមថ្លែងអំណរគុណចំពោះក្រុមការងារគំរោង " ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង " ដែលបានចំណាយពេលវេលាធ្វើការតាមយុទ្ធវិធី និងមធ្យោបាយផ្សេងៗ ដើម្បីសំរបសំរួលខ្លួនទឹងល័ក្ខខ័ណ្ឌសហគមន៍មូលដ្ឋាន ។ លោក តឹម ណុង និង លោក អ៊ុក លីឃីម គឺជាអ្នកបង្កើតឱ្យមានការរៀបចំការងារដោយសហគមន៍នេះឡើង ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះបណ្ឌិត **Gary Newkirk** ដែលបានផ្តល់ការគាំទ្រជាប្រចាំ និងឥតឈប់ឈរដល់គំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង" និងដែលបានសំរួលនូវទំនាក់ទំនងក្នុងការជួយកសាងឯកសារបង្រៀននេះ ។

ការរៀបចំឯកសារនេះទទួលបានជោគជ័យក៏អាស្រ័យដោយការជួយបរិច្ចាគជាថវិកាពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ(IDRC) អង្គការ WWF អង្គការ Oxfam អាមេរិកាំង និង អង្គការ Oxfam អង់គ្លេស ។

Rebecca Rivera-Guieb and
Melissa Marschke

ខែសីហា ឆ្នាំ 2001



# មាតិកាអត្ថបទ

ទំព័រ

**សេចក្តីថ្លែងអំណរគុណ**........................................1

**សេចក្តីផ្តើម**

មូលហេតុនៃការរៀបចំឯកសារ........................................1

គំរោង និងស្ថាប័នជាដៃគូរសហប្រតិបត្តិការ........................................1

អ្នកប្រើប្រាស់ឯកសារនេះ........................................2

របៀបប្រើឯកសារនេះ........................................2

**ផ្នែកទី១: ការណែនាំឱ្យស្គាល់គ្នា និងការរំពឹងទុក**........................................3

ការបង្កើតភាពស្និទ្ធស្នាល........................................3

ការពិនិត្យលើការរំពឹងទុក........................................4

**ផ្នែកទី២: ការបង្ហាញជូនអំពីសហគមន៍នេសាទ**........................................5

**ផ្នែកទី៣: ការប្រើប្រាស់នូវធនធានជលផល**........................................8

ល្បែងអំពីការនេសាទ........................................8

ការប្រើប្រាស់ជាទូទៅនូវធនធានជលផលទឹកសាប និងសមុទ្រ........................................12

ការចែករំលែកអំណាចៈ វិធីនានាសំរាប់គ្រប់គ្រងធនធានធម្មជាតិ........................................13

ការចូលរួមក្នុងការគ្រប់គ្រងជលផល........................................15

**ផ្នែកទី ៤: ការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ**........................................16

តំណាក់កាលជាគន្លឹះក្នុងការគ្រប់គ្រងសហគមន៍នេសាទ........................................18

**ផ្នែកទី៥: ការចូលរួម និងការគ្រប់គ្រងសហគមន៍នេសាទ**........................................21

លំហាត់ស្តីពីការចូលរួមៈ ការតភ្ជាប់រវាងចំនុចមួយទៅចំនុចមួយ........................................21

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសហគមន៍នេសាទ........................................22

**ផ្នែកទី៦: ការធ្វើផែនការសំរាប់ការចូលរួមគ្រប់គ្រងធនធាន**........................................25

លំហាត់ស្តីពីការចូលរួមដោះស្រាយបញ្ហា........................................25

**ផ្នែកទី៧: ការពិចារណាអំពីការគ្រប់គ្រងសហគមន៍នេសាទ ក្នុងប្រទេសកម្ពុជា** ........ 27

**ផ្នែកទី៨: មធ្យោបាយសំរាប់ការធ្វើផែនការគ្រប់គ្រងធនធាន ដោយមានការចូលរួម** ........ 30

ការធ្វើផែនការសំរាប់ការចូលរួមគ្រប់គ្រងធនធាន ........ 30

ការកំណត់ និងវិភាគបញ្ហា ........ 30

ការវិភាគអំពីភាគីពាក់ព័ន្ធ ........ 34

ការកំនត់គោលដៅ គោលបំនង យុទ្ធសាស្រ្ត និងសកម្មភាព ........ 35

រៀបចំកក្តាចង្អុលបង្ហាញ និងធ្វើផែនការសកម្មភាព ........ 37

**ផ្នែកទី៩: ការធ្វើសំយោគលទ្ធផលវគ្គបណ្តុះបណ្តាល** ........ 41



# សេចក្ដីផ្ដើម

## មូលហេតុនៃការរៀបចំឯកសារ

គំនិតផ្ដួចផ្ដើមក្នុងការរៀបចំឯកសារនេះ គឺជាមធ្យោបាយដ៏មានប្រយោជន៍ ដើម្បីជួយអ្នកសំរបសំរួលអនុវត្តការគ្រប់គ្រងសហគមន៍នេសាទ ។ ដោយសារនៅប្រទេសកម្ពុជាមានកង្វះខាតឯកសារស្ដីពីការចូលរួមគ្រប់គ្រងសហគមន៍នេសាទ យើងគិតថា គួរចាប់ផ្ដើមពីឯកសារការងារមូលដ្ឋានស្ដីពីការចូលរួមគ្រប់គ្រងសហគមន៍នេសាទនេះ ដែលពិពណ៌នាអំពីសកម្មភាព និងមធ្យោបាយខ្លះៗ ដែលអាចប្រើប្រាស់ក្នុងការគ្រប់គ្រងផលផល ។ ទោះបីមានការរៀបចំសិក្ខាសាលាជាច្រើនក្រោមប្រធានបទទាក់ទងនឹងការគ្រប់គ្រងធនធានជលផល ហើយក្ដី ក៏មនុស្សជាច្រើននៅតែបន្តសួរថា **តើយើងរៀបចំសហគមន៍នេសាទដោយរបៀបណា ?** ។ ឯកសារ អាចប្រើប្រាស់ជាមធ្យោបាយ ជាគំនិត និងសកម្មភាព ដែលអាចជួយអ្នកសំរបសំរួលក្នុងការស្រាវជ្រាវបន្ថែមទៀតលើប្រធានបទនេះ ក្នុងពេលធ្វើការជាមួយសហគមន៍នេសាទ ។

## គំរោង និងស្ថាប័នជាដៃគូសហប្រតិបត្តិការ

ការផ្ដួចផ្ដើមនេះបានចាប់ផ្ដើមពីគំរោង " ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង " ដែលទ្រទ្រង់ដោយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ(IDRC) និងដោយមានការជួយជ្រោមជ្រែងពីស្ថាប័នជាដៃគូក្នុងប្រទេសហ្វីលីពីន ដើម្បីជួយសំរួលការរៀបចំសិក្ខាសាលាស្រាវជ្រាវអំពីសហគមន៍នេសាទ ។ ជាលទ្ធផល គំរោង CBCRM LeaRN ដែលជាគំរោងមួយផ្សេងទៀតទ្រទ្រង់ដោយ IDRC បានសហការជាមួយគំរោង "ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង " រៀបរៀងឯកសារបង្រៀននេះឡើង ។

គំរោង CBCRM LeaRN កំពុងអនុវត្តដោយមជ្ឈមណ្ឌល "គ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍" ដែលជាអង្គការក្រៅរដ្ឋាភិបាល ចំនុះឱ្យមហាវិទ្យាល័យកិច្ចការសង្គម និងការអភិវឌ្ឍន៍សហគមន៍នៃសកលវិទ្យាល័យហ្វីលីពីន ។ គំរោងនេះ ធ្វើការសិក្សាស្រាវជ្រាវក្នុងតំបន់ និងផ្លាស់ប្តូរបទពិសោធន៍រវាងគ្នា ជាមួយសកលវិទ្យាល័យ Dalhousie និងមជ្ឈមណ្ឌលសំរាប់ការគ្រប់គ្រងដោយសហគមន៍នៃសកលវិទ្យាល័យ St Francis Xavier ដែលសកលវិទ្យាល័យទាំងពីរនេះស្ថិតនៅខេត្ត Nova Scotia ប្រទេស កាណាដា ។

## អ្នកប្រើប្រាស់ឯកសារនេះ

អ្នកដែលត្រូវការប្រើប្រាស់ឯកសារនេះ គឺជាអ្នកសំរបសំរួល ដែលធ្វើការជាមួយសហគមន៍ផ្នែកគ្រប់គ្រងធនធាន និងជាពិសេស ការគ្រប់គ្រងធនធានជលផល ។ យើងសង្ឃឹមថា អ្នកសំរបសំរួលអាចមកពីស្ថាប័ននានាដូចជា នាយកដ្ឋានជំនាញ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងប្រធានសហគមន៍ ហើយដែលអាចប្រើប្រាស់គំនិតក្នុងឯកសារនេះ សំរាប់អនុវត្តក្នុងការងារសហគមន៍ ។

## របៀបប្រើឯកសារនេះ

ដើម្បីឱ្យការប្រើប្រាស់ឯកសារនេះភាពងាយស្រួល អ្នកសំរបសំរួលគួរតែបានចូលរួមវគ្គបណ្តុះបណ្តាលអំពី "ការគ្រប់គ្រងសហគមន៍នេសាទ" ។ ក្នុងឯកសារនេះមានការពន្យល់ពីសកម្មភាព ការបង្ហាញជាឧទាហរណ៍ និងមានផ្តល់នូវកំណត់សំគាល់បន្ថែមទៀតដល់អ្នកសំរបសំរួលសំរាប់ធ្វើការពិចារណា ប៉ុន្តែផ្នែកខ្លះនៃពិតមានដែលមានក្នុងសៀវភៅនេះអាចប្រើប្រាស់បានយ៉ាងសមស្រប ។ ការសំរបសំរួលបានល្អ គឺជាការពន្យល់បានក្បោះក្បាយ និងមានភាពសមស្រប ហើយលោកអ្នកអាចប្រើប្រាស់គំនិត និងវិធីសាស្ត្រដែលមានក្នុង ឯកសារនេះសំរាប់ណែនាំក្នុងការងាររបស់អ្នក ។

នេះជាជំហានទីមួយក្នុងការរៀបចំឯកសារ ហើយការប្រើប្រាស់អាចមានការផ្លាស់ប្តូរ និងមានការសំរបសំរួលទៅតាមពេលវេលា និងទីកន្លែងជាក់ស្តែងចាំបាច់ ។ យើងអាចចាត់ទុកថា នេះគឺជាការចាប់ផ្តើម សំរាប់អ្នកសំរបសំរួលដែលធ្វើការក្នុងផ្នែកគ្រប់គ្រងធនធានដោយសហគមន៍ ។

## ផ្នែកទី១: ការណែនាំឱ្យស្គាល់គ្នា និងការរំពឹងទុក

### ការបង្កើតភាពស្និទ្ធស្នាល

ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល មិនមែនជាកិច្ចការងាយស្រួលទេសំរាប់អ្នកសំរបសំរួលជាពិសេសនៅពេលសិក្ខាកាមទាំងឡាយមិនទាន់ស្គាល់គ្នា ។ ដើម្បីសំរួលការងារនេះ យើងមានល្បែងសកម្មភាព និងលំហាត់មួយចំនួន ដែលអ្នកសំរបសំរួលអាចប្រើប្រាស់សំរាប់ណែនាំដើម្បី "បង្កើតភាពស្និទ្ធស្នាល" ។



ឧទាហរណ៍: មានសកម្មភាពមួយដែលគេឱ្យឈ្មោះថា "គំនូររូបខ្ញុំ" ។ ដើម្បីអនុវត្តសកម្មភាពនេះ អ្នកសំរបសំរួលត្រូវចែកក្រដាស និងហ្វឺតពណ៌ដល់សិក្ខាកាមគ្រប់ៗគ្នា ។ សិក្ខាកាមត្រូវបានស្នើឱ្យគូររូបខ្លួនឯងផ្ទាល់ តាមការចូលចិត្តរៀងៗខ្លួន ។ បន្ទាប់មក នៅខាងក្រោមរូបគំនូរ សិក្ខាកាមម្នាក់ៗត្រូវសរសេរពតិមានបីចំនុចអំពីខ្លួនឯង ដែលអាចណែនាំដល់សិក្ខាកាមទាំងអស់ដើម្បីស្គាល់គ្នាទៅវិញទៅមកបាន ដូចជា តើខ្លួនជានរណា មកពីណា អ្វីខ្លះដែលខ្លួនចូលចិត្ត ។ ក្រោយពេលដែលគ្រប់គ្នាបានសរសេររួចរាល់ហើយ សិក្ខាកាមម្នាក់ៗត្រូវបង្ហាញរូបដែលខ្លួនបានគូរ និងពន្យល់អំពីរូបនោះ ។

## សំនួរណែនាំសំរាប់អ្នកសំរបសំរួលៈ

1. តើការនិយាយអំពីខ្លួនឯងប្រាប់អ្នកដទៃ មានការលំបាក ឬក៏ងាយស្រួល ? ហេតុអ្វី ?
2. តើអ្នកគិតថា យើងគួរធ្វើអ្វីខ្លះដើម្បីឱ្យមានអារម្មណ៍ស្រួលក្នុងវគ្គបណ្តុះបណ្តាលនេះ?

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួលៈ

ការជ្រើសរើសសកម្មភាពណែនាំឱ្យសិក្ខាកាមទាំងអស់ស្គាល់គ្នា ជាប្រការសំខាន់ណាស់នៅគ្រប់វគ្គបណ្តុះបណ្តាល ជាពិសេសប្រសិនបើពួកគេពុំទាន់ស្គាល់គ្នានៅឡើយ ។ ដើម្បីឱ្យសិក្ខាកាមមានអារម្មណ៍ធូរស្រាលនៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល អ្នកសំរបសំរួល គួរផ្តល់ពេលវេលាគ្រប់គ្រាន់សំរាប់ការណែនាំឱ្យស្គាល់គ្នា និងបង្កើតភាពស្និទ្ធស្នាល ។ ឧទាហរណ៍ផ្សេងៗនៃសកម្មភាពខាងលើ នឹងមានភ្ជាប់ជូននៅផ្នែកខាងក្រោយនៃសៀវភៅនេះ ។

## ការពិនិត្យលើការរំពឹងទុក

អ្នកសំរបសំរួល ចាំបាច់ត្រូវពិនិត្យមើលការរំពឹងទុករបស់សិក្ខាកាម ដែលជាផ្នែកមួយនៃការត្រួតពិនិត្យដំនើរការណែនាំឱ្យស្គាល់គ្នា ។ ដើម្បីធ្វើបែបនេះបាន អ្នកសំរបសំរួលអាចណែនាំសកម្មភាពមួយទៀតហៅថា "សេចក្តីសង្ឃឹមចំបងៗ" ។ ឧទាហរណ៍ : អ្នកសំរបសំរួលត្រូវចែកឱ្យសិក្ខាកាមនូវក្រដាសដែលកាត់ជារូបត្រី ស្មៅសមុទ្រ រូបគ្រឿងផ្ទុះ និងហ៊ីតពណិ ។ បន្ទាប់មក អ្នកសំរបសំរួលត្រូវប្រាប់សិក្ខាកាមថា រូបត្រីតំណាងឱ្យការរំពឹងទុកមួយអំពីការបណ្តុះបណ្តាល រូបស្មៅសមុទ្រជាតំណាងឱ្យប្រវត្តិ ឬបទពិសោធន៍របស់អ្នកណាម្នាក់ ហើយគ្រឿងផ្ទុះជាតំណាងឱ្យការភ័យខ្លាច ឬការព្រួយបារម្មណ៍ដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ។ អ្នកសំរបសំរួលត្រូវផ្តល់ពេល ១០នាទី សំរាប់សិក្ខាកាមសរសេរអំពីគំនិត របស់ពួកគាត់ បន្ទាប់មកក្រដាសទាំងនោះត្រូវយកទៅបិទជាប់នឹងក្តារខៀន ។ សិក្ខាកាម ត្រូវប្តូរវេនគ្នា

ដើម្បីឆ្លើយនឹងសំណួររបស់ក្រុមទាំងមូល ។ សកម្មភាពនេះនឹងត្រូវបញ្ចប់ ក្រោយពីអ្នកសំរបសំរួលធ្វើសេចក្តីសង្ខេបអំពីចំលើយទាំងអស់របស់សិក្ខាកាម ។

## សំនួរណែនាំសំរាប់អ្នកសំរបសំរួលៈ

1. តើការរំពឹងទុករួមរបស់សិក្ខាកាមមានអ្វីខ្លះ ? តើវគ្គបណ្តុះបណ្តាលអាចបំពេញបានតាមការរំពឹងទុកទាំងនោះបានទេ ? តើការរំពឹងទុកណាខ្លះដែលមិនអាចបំពេញបាន ?
2. តើអ្វីខ្លះជាការព្រួយបារម្ភ ឬភាពធុញថប់រួម? តើអាចធ្វើអ្វីខ្លះដើម្បីជំនះកត្តាទាំងនេះ?

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួលៈ

រូបតំណាង "សេចក្តីសង្ឃឹមចំបង១" គួរតែទុកនៅកន្លែងណាមួយដែលសិក្ខាកាមទាំងអស់អាចមើលឃើញគ្រប់ពេលនៃវគ្គបណ្តុះបណ្តាល ។ ប្រការសំខាន់ គឺអ្នកសំរបសំរួលគួរព្យាយាមធ្វើការឆ្លើយតបជាបន្ទាន់ ចំពោះកង្វល់ណាមួយដែលក្រុមទាំងមូលអាចមាន និងត្រូវជំរុញទឹកចិត្តរកដំណោះស្រាយជាក្រុមចំពោះកង្វល់នេះ ។ នេះជាប្រការសំខាន់ដែលអ្នកសំរបសំរួលត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់អំពីប្រវត្តិរបស់សិក្ខាកាមម្នាក់ៗ ។ នៅក្នុងពេលធ្វើការបណ្តុះបណ្តាល អ្នកសំរបសំរួលអាចស្នើឱ្យសិក្ខាកាមខ្លះពិភាក្សាបន្ថែម អំពីប្រធានបទជាក់លាក់មួយចំនួន ។

# ផ្នែកទី២: ការបង្ហាញជូនអំពីសហគមន៍នេសាទ

ការធ្វើប្លង់ គឺជាមធ្យោបាយមួយ ដើម្បីជួយសិក្ខាកាមឱ្យពន្យល់អំពីស្ថានភាពភូមិរបស់ពួកគាត់ ។ ដើម្បីធ្វើឱ្យសកម្មភាពនេះគួរជាទីចាប់អារម្មណ៍ គេធ្វើប្លង់គំរូក្នុងលំហរ ដែលអាចផ្តល់ឱកាសដល់សិក្ខាកាមឱ្យមានគំនិតផ្តួចផ្តើម និងបញ្ចេញទស្សនៈរបស់ខ្លួនតាមវិធីផ្សេងៗ អំពីលក្ខខ័ណ្ឌនៃធនធានជលផល និងតំបន់នេសាទ ។

សំរាប់ការរៀបចំនេះ គេអាចប្រើមៀ្សរាំជ្រើមទឹកដោយលាយពណ៌ផ្សេងៗ និងសំភារៈសំរាប់គូរគំនូរ ។ សិក្ខាកាមត្រូវបានណែនាំឱ្យសង់ " ប្លង់គំរូ " អំពីសហគមន៍តំបន់ឆ្នេរ



សហគមន៍នេសាទ ឬសហគមន៍តំបន់ខ្ពង់រាប ទៅតាមការយល់ឃើញ និងការពិនិត្យឃើញរបស់ពួកគាត់ ( អ្នកសំរបសំរួល អាចធ្វើការសំរេចចិត្តអំពីប្រភេទប្លង់សហគមន៍ ដោយអាស្រ័យតាមសិក្ខាកាមក្នុងសិក្ខាសាលា ក្នុងករណីសិក្ខាកាមមកពីសហគមន៍ច្រើន ត្រូវបែងចែកសិក្ខាកាមជាក្រុម តាមសហគមន៍ និងធ្វើប្លង់គំរូសហគមន៍របស់គាត់ ) ។ សិក្ខាកាមអាចប្រើប្រាស់វត្ថុផ្សេងដូចជា ដុំថ្ម កំណាត់ឈើ ស្លឹក ឬផ្លែឈើ ។ល។ ក្រោយពេលសិក្ខាកាមទាំងអស់រៀបចំរួចស្រេចបាច់ហើយ ពួកគាត់អាចពន្យល់បង្ហាញអំពីលទ្ធផលនៃការងារ ដោយពិភាក្សាអំពីគោលបំណង និងសកម្មភាពដែលមានបង្ហាញនៅក្នុងប្លង់គំរូ និងពិពណ៌នាអំពីសកម្មភាពដែលក្រុមទាំងមូលបានរៀបចំជាប្លង់សហគមន៍នេះឡើង ។



## ឧទាហរណ៍: ប្លង់គំរូសហគមន៍នេសាទតំបន់ឆ្នេរ

សិក្ខាកាមក្នុងក្រុមទាំងអស់ពិភាក្សាគ្នាថា តើគួរមានអ្វីខ្លះដែលត្រូវដាក់បញ្ចូលនៅក្នុងប្លង់សហគមន៍នេសាទតំបន់ឆ្នេររបស់ខ្លួន ។ ឧទាហរណ៍ : ពួកគាត់ចាប់ផ្តើមយកម្សៅសូនធ្វើជា ត្រី ទូក កោះ និងផ្ទះ ។ ម្សៅលាយពណ៌ក្រហមសូនធ្វើជាផ្ទះ និងវត្ត ។ ផ្លូវមួយត្រូវបានគូសភ្ជាប់ទៅកាន់សាលារៀន និងវត្ត ។ ពួកគាត់ក៏បានសូនរូបតំណាងព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម និងឆ្នេរខ្សាច់តូចមួយផងដែរ ។ ហើយមានអ្នកនេសាទជាច្រើននៅពីមុខឆ្នេរខ្សាច់ដែលតំណាងឱ្យសកម្មភាពនានានៅក្នុងតំបន់នេះ ។ កោះខ្លះត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនឯកជន និងខ្លះទៀតប្រើជាមូលដ្ឋានយោធា ។ មានទូកធំៗមួយចំនួនកំពុងនេសាទក្បែរសហគមន៍នេះ ។

### សំនួរណែនាំសំរាប់អ្នកសំរបសំរួល

1. តើវត្ថុនិមួយៗនៅក្នុងប្លង់គំរូតំណាងឱ្យអ្វីខ្លះ ?
2. តើមានការប្រើប្រាស់ធនធានបែបណាខ្លះ ដែលមានបង្ហាញនៅក្នុងប្លង់គំរូ ?
3. តើការប្រើប្រាស់ទាំងនេះបង្ហាញឱ្យឃើញទំនាស់រវាងគ្នា ឬក៏ជាការបំពេញគ្នាទៅវិញទៅមក ? ហេតុអ្វី ?
4. តើសកម្មភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតំណាងដោយអ្វី ?
5. តើសកម្មភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃមានកំរិតប្រហាក់ប្រហែលគ្នាដែរឬទេ ? ហេតុអ្វី ? តើមានសកម្មភាពណាខ្លះ ដែលអាចទំនាស់គ្នា ឬ បំពេញគ្នា ?
6. តើអ្វីដែលតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងប្លង់គំរូ ?
7. តើនៅក្នុងប្លង់គំរូមានរូបតំណាងឱ្យបុរស និងស្ត្រីដែរឬទេ ? ហេតុអ្វី ? ។ល។

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួល

ទាំងធនធានលើគោក និងធនធានក្នុងទឹក ត្រូវបានគេបង្ហាញនៅក្នុងប្លង់គំរូនៃសហគមន៍តំបន់នេសាទ ហើយអ្នកសំរបសំរួលអាចធ្វើការបកស្រាយលំអិតអំពីអន្តរអំពើរវាងធនធានទាំងនោះ ។ ប្រការនេះ អ្នកសំរបសំរួលត្រូវបង្ហាញពីការប្រើប្រាស់ផ្សេងៗនៃធនធាន និងសារៈសំខាន់របស់វា ។ គេគួរលើកទឹកចិត្តឱ្យមានការពិភាក្សាអំពីទំនាក់ទំនងរវាងមនុស្សជាមួយធនធានធម្មជាតិ ។ បន្ទាប់មកអ្នកសំរបសំរួលអាចអធិប្បាយលំអិតអំពីសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃដែលមានបង្ហាញនៅក្នុងប្លង់គំរូ ។ នៅចុងបញ្ចប់នៃកិច្ចពិភាក្សា អ្នកសំរបសំរួលត្រូវបញ្ជាក់ពីសារៈសំខាន់ នៃកត្តាមនុស្ស និងទំនាក់ទំនងរវាងមនុស្សក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ឧទាហរណ៍ ការដែលដឹងត្រឹមតែលក្ខណៈរូបនៃធនធាននៅមិនទាន់គ្រប់គ្រាន់ទេ គេចាំបាច់ត្រូវយល់អំពីរបៀបដែលមនុស្សប្រើប្រាស់ និងអន្តរអំពើរវាងមនុស្សជាមួយធនធានធម្មជាតិ ពោលគឺទំនាក់ទំនងរវាងមនុស្ស និងធនធានធម្មជាតិក្នុងមូលដ្ឋានរបស់គាត់ ( រួមទាំងតួនាទីផ្សេងៗគ្នារបស់បុរស និងស្ត្រីនៅក្នុងសហគមន៍) ។

# ផ្នែកទី៣: ការប្រើប្រាស់ទូទៅនៃធនធានជលផល

## ល្បែងអំពីការនេសាទ

ល្បែងអំពីការនេសាទត្រូវបានបង្កើតឡើងគំរូវទៅតាមសកម្មភាពនេសាទ និងដើម្បីផ្តល់ការបង្ហាញខ្លះៗ ដែលឆ្លើយតបនឹងមូលហេតុចាំបាច់ដែលធ្វើឱ្យការនេសាទមាននិរន្តភាព ។ គេចាំបាច់ត្រូវមានពេលវេលាគ្រប់គ្រាន់សំរាប់ពិភាក្សាអំពី "វិធាននៃល្បែងនេះ " មុនពេលចាប់ផ្តើមលេង ។

ជាដំបូង អ្នកសំរបសំរួលត្រូវបែងចែងសិក្ខាកាមទាំងអស់ជាក្រុមតូចៗ ហើយក្រុមនីមួយៗគួរមានសមាជិកពី ៨-១០នាក់ ។ ក្រុមនីមួយៗត្រូវការសំភារៈដូចតទៅ :

⇨ គ្រាប់ធញ្ញជាតិ ៤០គ្រាប់ ដែលមានពិណា ស ខ្មៅ និងលឿង (ដែលតំណាងឱ្យ ត្រីមេ ត្រីជំទង់ និងកូនត្រី)

⇨ ចានដែក ធុង ឬប្រអប់

⇨ គ្រាប់គ្រួស ឬស្មៅ

⇨ ម៉ាស៊ីនគិតលេខ

⇨ ក្រដាសផ្ទាំងធំ និងហ្វឺតសំរាប់សរសេរលើក្រដាសនោះ ។

បន្ទាប់មក អ្នកសំរបសំរួលត្រូវណែនាំឱ្យក្រុមទាំងអស់ វាយគ្រាប់ធញ្ញជាតិលាយជាមួយគ្រាប់គ្រួស ឬស្មៅ នៅក្នុងចានដែក ធុង ឬប្រអប់ និងសំរាប់ឱ្យអ្នកនេសាទត្រៀមខ្លួនដើម្បី "ចេញទៅនេសាទ" ។ អ្នកសំរបសំរួល ត្រូវកំនត់ពេលមួយនាទីសំរាប់មួយវគ្គនៃការធ្វើនេសាទ (ជួនកាលរយៈពេលបែបនេះអាចកែប្រែ អាស្រ័យលើការនេសាទយឺតឬលឿន) ។ វគ្គនៃការនេសាទនីមួយៗ តំណាងឱ្យរយៈពេលមួយឆ្នាំ ។ អ្នកនេសាទត្រូវបានណែនាំឱ្យធ្វើនេសាទតិច ឬច្រើនតាមតំរូវការនៅក្នុងពេលកំណត់មួយ ដោយមិនអនុញ្ញាតិឱ្យជជែកគ្នាទេ ។

នៅចុងវគ្គនេសាទនីមួយៗ អ្នកនេសាទម្នាក់ៗត្រូវរាប់ចំនួនត្រីដែលខ្លួននេសាទបាន នៅលើផ្ទាំងក្រដាសធំ និងគណនាចំនួនត្រីទាំងអស់នោះ ។ វិធានខាងក្រោមនេះ គឺជាការត្រួតពិនិត្យលើការនេសាទ :

⇨ នៅក្នុងឆ្នាំបន្ទាប់ កូនត្រីដែលនៅសល់នឹងធំធាត់ក្លាយទៅជាត្រីជំទង់ ។ ត្រូវរាប់ចំនួនកូនត្រីនៅសល់ដែលនឹងក្លាយទៅជាត្រីជំទង់នៅឆ្នាំទីពីរ ។

⇨ ត្រីធំ (ត្រីមេ) ទាំងអស់ដែលនៅសល់ពីការធ្វើនេសាទ បានបន្តពូជបន្ថែម (ចំនួនត្រីកើនឡើងទ្វេរ) ។ ត្រូវធ្វើការកត់ត្រាចំនួនកូនត្រីនៅឆ្នាំទីពីរ ដែលស្មើនឹងចំនួនត្រីមេដែលនៅសល់កាលពីឆ្នាំកន្លងទៅ ។

⇨ ត្រីជំទង់ដែលនៅសល់ពីការធ្វើនេសាទ ក៏ធំធាត់ក្លាយទៅជាត្រីមេ ។ បន្ថែមចំនួនត្រីជំទង់ ទៅក្នុងចំនួនត្រីមេដែលនៅសល់ពីការធ្វើនេសាទកាលពីឆ្នាំកន្លងទៅ ។ កត់ត្រាចំនួនត្រីមេសរុបនៅក្នុងឆ្នាំទីពីរ ។

ក្រោយពីធ្វើការគណនារួចហើយ ការនេសាទសំរាប់វគ្គបន្ទាប់ក៏ចាប់ផ្តើម ។ បន្ទាប់ពីការធ្វើនេសាទបានបីវគ្គរួចមក សមាជិកដែលជាតំណាងក្រុមនីមួយៗ នឹងចេញមកបង្ហាញពីលទ្ធផលនៃការគណនារបស់ក្រុមខ្លួនដល់ក្រុមដទៃទៀត ។

## ឧទាហរណ៍បង្ហាញពីលទ្ធផលនៃល្បែងអំពីការនេសាទ

| ឆ្នាំទី | ចំនួនត្រីមុនពេលធ្វើការនេសាទ | | | ផលនេសាទសរុប | | | ចំនួនត្រីនៅចុងឆ្នាំ | | |
|---|---|---|---|---|---|---|---|---|---|
| | ក | ខ | គ | ក | ខ | គ | ក | ខ | គ |
| 1 | 40 | 40 | 40 | 15 | 30 | 17 | (40-15) =25 | (40-30) =10 | (40-17) =23 |
| 2 | (10+25) =35 | 23 | 25 | | | | | | |
| 3 | | | | | | | | | |

<u>កំណត់សំគាល់</u>

ក. ត្រីមេ



ខ. ត្រីជំទង់



គ. កូនត្រី



## សំនួរណែនាំសំរាប់អ្នកសំរបសំរួល

1. តើសមាជិកក្រុមទាំងឡាយបានធ្វើការនេសាទបែបណា ? តើអ្នកនេសាទទាំងនោះចាប់អារម្មណ៍ពីរបៀបធ្វើនេសាទរបស់អ្នកដទៃដែរឬទេ ?
2. តើចំនួនត្រីសរុបកើនឡើង ឬថយចុះ ។ ហេតុអ្វី ?

3. តើអ្នកនេសាទម្នាក់ៗមានអារម្មណ៍បែបណាដែរ នៅពេលដែលផលនេសាទកាន់តែតិចទៅៗ ?
4. តើផលនេសាទរបស់ពួកគាត់ម្នាក់ៗដូចគ្នាដែរឬទេ ? ហេតុអ្វី ?
5. តើមានអ្នកនេសាទណាម្នាក់មានអារម្មណ៍ចង់ធ្វើអ្វីម្យ៉ាង ដើម្បីឆ្លើយតបនឹង ផលនេសាទ ឬបរិមាណត្រីដែលថយចុះដែរឬទេ ? បើមាន តើគាត់ចង់ធ្វើបែបណា ?

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួល

ល្បែងអំពីការនេសាទផ្តល់ឱកាសដល់អ្នកសំរបសំរួលក្នុងការស្វែងយល់ថា តើហេតុអ្វីទើបគេចាត់ទុកការគ្រប់គ្រងផលផលមានសារៈសំខាន់ ។ ការពិភាក្សាអាចផ្តោតលើចំណាប់អារម្មណ៍របស់សិក្ខាកាម ឱ្យឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងល្បែង ជាមួយស្ថានភាពជាក់ស្តែងនៃការនេសាទនៅក្នុងសហគមន៍របស់ពួកគាត់ ។



សកម្មភាពបន្ទាប់ដែលគួរលើកយកមកអនុវត្ត គឺជាល្បែងនេសាទទីពីរ ។ លើកនេះសិក្ខាកាមត្រូវបានណែនាំឱ្យពិភាក្សាអំពីវិធានធ្វើនេសាទ មុនពេលចេញទៅនេសាទ ។ ក្រុមទាំងឡាយមានពេល ១៥នាទី ដើម្បីជ្រើសរើស ឬឯកភាពលើវិធាននៃការនេសាទ និងស្នើឱ្យគោរពតាមវិធានដូចដែលបានអនុវត្តនៅក្នុងល្បែងនេសាទលើកដំបូង ។

ឧទាហរណ៍ខ្លះៗនៃវិធានដែលសិក្ខាកាមអាចប្រើប្រាស់ក្នុងល្បែងបន្ទាប់រួមមាន :

⇨ ដាក់កំហិតចំពោះឧបករណ៍នេសាទ

⇨ ការកំនត់តំបន់ ឧទាហរណ៍ តំបន់មួយចំនួនត្រូវបានកំនត់ជា "តំបន់ហាមឃាត់ការធ្វើនេសាទ"

⇨ កំនត់រដូវនេសាទ

⇨ តាមដានជាប្រចាំនូវភាពប្រែប្រួលនៃបរិមាណត្រីក្នុងធម្មជាតិ

⇨ ធ្វើផែនការនេសាទដែលមានរួមបញ្ចូលវិធានការណ៍ការពារ និងអភិរក្ស ។

បរិមាណត្រីដែលនៅសល់ពីការនេសាទក្នុងវគ្គទីមួយ និងវគ្គទីពីរនៃល្បែងនេសាទ មិនដូចគ្នាទេ ។ នៅពេលពិភាក្សាអំពីការលេងល្បែងក្នុងវគ្គទីពីរ អ្នកសំរបសំរួលអាចផ្តោតអារម្មណ៍ថា តើវិធាននេសាទ ត្រូវបានរៀបចំដោយរបៀបណា ហើយវាជះឥទ្ធិពលដល់បរិមាណត្រីបែបណា ។

## ការប្រើប្រាស់ជាទូទៅនូវធនធានដលទលទឹកសាប និងសមុទ្រ

បច្ចេកសព្ទមួយចំនួនដែលមានប្រើប្រាស់ក្នុងការគ្រប់គ្រងតំបន់ឆ្នេរ:

CZM - Coastal Zone Management
(ការគ្រប់គ្រងតំបន់ឆ្នេរ)

ICZM - Integrated Coastal Zone Management

ICM - Integrated Coastal Management

ICAM - Integrated Coastal Area Management

(ពាក្យទាំងបីខាងលើអាចមានន័យជាភាសាខ្មែរថា: ការគ្រប់គ្រងតំបន់ឆ្នេរតាមបែបសមាហរណកម្ម ការគ្រប់គ្រងចំរុះបរិស្ថានតំបន់ឆ្នេរ ការគ្រប់គ្រងចំរុះតំបន់ឆ្នេរ)

CRM - Coastal Resource Management (ការគ្រប់គ្រងធនធានតំបន់ឆ្នេរ)

CBCRM- Community Based Coastal Resource Management

(ការគ្រប់គ្រងធនធានតំបន់ឆ្នេរដោយសហគមន៍)

ស្ថានភាពនៃការនេសាទ ដោយសេរី មិនមែនមានន័យថា សហគមន៍ទាំងអស់ អាចនេសាទបានស្មើៗគ្នានោះទេ ។ ជាទូទៅ អ្នកដែលមានឧបករណ៍នេសាទ ធំជាងគេអាចទៅនេសាទបានច្រើនជាង ។ លើសពីនេះ នៅមានវិធាននេសាទមិនប្រក្រតីជាច្រើន ក្នុងសហគមន៍នេសាទ ដែលប្រជាពលរដ្ឋរកឃើញ ពោលគឺ ប្រពៃណី ទំនៀមទំលាប់ និងជំនឿ ដែលជា កត្តាជះឥទ្ធិពលដល់ការនេសាទ ។

ធនធានជលផលទាំងនៅដែនទឹកសាបនិងសមុទ្រ ច្រើនតែត្រូវបានចាត់ទុកជាធនធានដែលអាចប្រើប្រាស់បានដោយសេរី ។ ប៉ុន្តែផ្នែកខ្លះនៃដែននេសាទទឹកសាបក្នុងប្រទេសកម្ពុជា បានដាក់កំហិតដល់សមាជិកសហគមន៍ក្នុងការធ្វើនេសាទ ជាពិសេសតំបន់មួយចំនួននៅជុំវិញបឹងទន្លេសាប ។ មានតែតំបន់ឆ្នេរទេ ដែលភាគច្រើននៃដែននេសាទ ត្រូវបានចាត់ទុកជា "សម្បត្តិរួម" ។ ក្នុងស្ថានភាពសម្បត្តិរួម ពុំមានអ្នកណាម្នាក់ធ្វើជាម្ចាស់លើធនធាន ហើយគ្រប់ៗគ្នាអាចប្រើប្រាស់ធនធានទាំងនោះបាន ។ ក្រោមរូបភាពបែបនេះ ប្រជាពលរដ្ឋទាំងឡាយអាចធ្វើការនេសាទ ( មានមនុស្សជាច្រើននេសាទច្រើនហួសហេតុ) ហើយជាទូទៅពួកគាត់ធ្វើការនេសាទគ្មានឈប់ឈរ រហូតទាល់តែគ្មានសល់ធនធានសំរាប់ប្រើប្រាស់បន្ត ។

## ការគ្រប់គ្រងជលផលៈ ឧទាហរណ៍មួយដកស្រង់ពីតំបន់ឆ្នេរ

ធនធានជលផលទឹកសាប និងតំបន់ឆ្នេរមានលក្ខណៈទូទៅមួយចំនួន ។ ឧទាហរណ៍ៈ ក្នុងតំបន់ឆ្នេរ មានបញ្ហាចំបងបី : (ក) មានការលំបាកក្នុងការកំនត់ព្រំប្រទល់ (ខ) មានបញ្ហាទំនាស់ជាច្រើន (គ) ការកំណត់ភាពជាម្ចាស់ មានការលំបាក ។ ដើម្បីឆ្លើយតបនឹងបញ្ហាធនធាន គឺត្រូវការការគ្រប់គ្រងជាប្រចាំ ។

## ការចែករំលែកអំណាច : វិធីសាសំរាប់គ្រប់គ្រងធនធានធម្មជាតិ

តំនូរដ្យាក្រាមខាងក្រោមបង្ហាញពីការគ្រប់គ្រងដោយសហគមន៍ ការគ្រប់គ្រងដោយរដ្ឋាភិបាល និងសហគ្រប់គ្រង ដែលអាចមានទំនាក់ទំនងរវាងគ្នា ។ ការពិភាក្សាអំពីការគ្រប់គ្រងដោយសហគមន៍ ដោយដាក់បញ្ចូលជាសហគ្រប់គ្រង មានសារៈសំខាន់ណាស់ សំរាប់ស្ថានភាពក្នុងប្រទេសកម្ពុជា ដោយសារកំណែទំរង់ក្នុងវិស័យជលផលនៅមានជាបន្តបន្ទាប់ និងអនុក្រិត្យស្តីពីសហគមន៍នេសាទកំពុងទន្ទឹងរង់ចាំការអនុម័ត ។



ប្រភព : Promeroy, R. (1999)

ក្នុងប្រទេសកម្ពុជា មានឧទាហរណ៍ជាច្រើន ទាក់ទងនឹងសហគមន៍ គ្រប់គ្រងធនធានជលផល ដូចជា សហគ្រប់គ្រងធនធានជលផល (ការចែករំលែកអំណាចរវាងរដ្ឋាភិបាល និងសហគមន៍) និងការគ្រប់គ្រងដោយសហគមន៍ ។ ប្រសិនបើចង់ឱ្យការគ្រប់គ្រងប្រព្រឹត្តទៅបានល្អ រដ្ឋាភិបាល និងសហគមន៍ ត្រូវធ្វើការជាមួយគ្នា ដើម្បីស្វែងរកដំណោះស្រាយរួម ក្នុងការគ្រប់គ្រងជលផល ។



## ការចូលរួមក្នុងការគ្រប់គ្រងផលផល

ការគ្រប់គ្រងសហគមន៍នេសាទអាស្រ័យដោយការចូលរួមរបស់ប្រជាពលរដ្ឋ : នេះជាកត្តាដ៏សំខាន់នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ ប៉ុន្តែការចូលរួមមិនមែនសុទ្ធតែប្រព្រឹត្តទៅដោយឯកឯង និងងាយស្រួលគ្រប់ករណីនោះទេ ព្រោះថា ផលប្រយោជន៍ និងវត្ថុលើកទឹកចិត្តសំរាប់ការចូលរួម ចាំបាច់ត្រូវតែបង្ហាញឱ្យសហគមន៍បានឃើញច្បាស់ ។ នេះមានន័យថាប្រជាពលរដ្ឋត្រូវការដឹងពីមូលហេតុ ដែលមានសារៈសំខាន់ក្នុងការចូលរួមរបស់ពួកគាត់ ហើយការចូលរួមនេះ មានទំនាក់ទំនងបែបណាជាមួយជីវភាពរស់នៅរបស់ពួកគាត់ ។



**ចំណុចដូចខាងក្រោមនេះមានសារៈសំខាន់ណាស់នៅក្នុងការគ្រប់គ្រងដោយសហគមន៍ :**

1. **ការធ្វើការជាមួយគ្នា** – ការគ្រប់គ្រងដោយសហគមន៍ សំដៅចំពោះប្រជាពលរដ្ឋធ្វើការរួមគ្នា ដើម្បីគ្រប់គ្រងធនធានធម្មជាតិ ។

2. **ការសំរបសំរួល** – កិច្ចសហការរវាងភាគីពាក់ព័ន្ធនានា ជាប្រការសំខាន់ណាស់ក្នុងការគ្រប់គ្រងដោយសហគមន៍ ទោះបីជាគោលដៅចំបង ផ្តោតជាសំខាន់តែលើសហគមន៍ក៏ដោយ ។ ឧទា. កិច្ចសហការរវាងសហគមន៍ជាមួយរដ្ឋាភិបាល ដើម្បីពង្រីកការគាំទ្រសំរាប់កិច្ចការគ្រប់គ្រង ។
3. **ការអប់រំ និងការចូលរួម** – ការបង្កើនមនសិការ ការកសាងចំណេះដឹង និងការអប់រំ គឺជាកត្តាសំខាន់ក្នុងការគ្រប់គ្រងដោយសហគមន៍។
4. **សម្ពាធអន្តរជាតិ** – គេបានដឹងថា ព្រឹត្តិការណ៍ និងការអភិវឌ្ឍន៍នៅក្រៅប្រទេសអាចជះឥទ្ធិពលដល់ការគ្រប់គ្រងធនធានធម្មជាតិ នៅពេលដែលការគ្រប់គ្រងដោយសហគមន៍ផ្តល់អាទិភាពដល់សហគមន៍ដែលពាក់ព័ន្ធ ។

## ផ្នែកទី ៤: ការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ

ការគ្រប់គ្រងធនធាននេសាទ ត្រូវបានគេកំពុងអនុវត្តគ្រប់ទីកន្លែងនៅលើពិភពលោករួមទាំងប្រទេសកម្ពុជាផងដែរ ។ សិក្ខាសាលា គឺជាឱកាសសំរាប់ឱ្យភាគីពាក់ព័ន្ធនានា (សមាជិកសហគមន៍ មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល) ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកអំពីការគ្រប់គ្រងធនធាននេសាទ ។ គួរកត់សំគាល់ថា គំរោងស្តីពីការគ្រប់គ្រងព្រៃឈើ ឬគំរោងស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ក៏ផ្តោតការយកចិត្តទុកដាក់អំពីការគ្រប់គ្រងជលផលដែរ ។

ស្នើឱ្យសិក្ខាកាមពិភាក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍ គ្នាទៅវិញទៅមក ។

## ករណីសិក្សា: ឧទ្យានជាតិរាម

ឧទ្យានជាតិរាមមានក្រលាផ្ទៃ២១.០០០ហិកតា ។ កាលពីដំបូង ប្រជាពលរដ្ឋកត់សំគាល់ឃើញថា ធនធានជលផលកាន់តែហិនហោចទៅៗ គឺភាគច្រើនដោយសារសកម្មភាពនេសាទល្មើសច្បាប់ ។ ប្រជាពលរដ្ឋបានធ្វើការប្រឆាំងនឹងការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ ដោយធ្វើបាតុកម្ម ដើម្បីបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនក្នុងការបញ្ឈប់ទំលាប់នេសាទល្មើសច្បាប់ ។ ដោយរួមសហការជាមួយរដ្ឋាភិបាលសហគមន៍នៅរាម ចាប់ផ្តើមពិភាក្សាអំពីអ្វីដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហានេះ ។

ជាដំបូង សហគមន៍បានរៀបចំក្នុងភូមិចំនួនប្រាំបួន ហើយការបោះឆ្នោតជ្រើសរើសគណៈកម្មាការភូមិ និងបទបញ្ជារបស់សហគមន៍ក៏បានបង្កើតឡើង ។ បទបញ្ជាថ្នាក់ភូមិនេះ បានទទួលការគាំទ្រពីក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋាន ។ ប៉ុស្តិ៍ត្រួតពិនិត្យក៏បានកសាងឡើងសំរាប់ឱ្យប្រជានេសាទ សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីបច្ចេកទេសធ្វើការយាមល្បាត ។ ឧទាហរណ៍ មានប្រជានេសាទបួននាក់យាមល្បាតពេញមួយថ្ងៃ (មកពីភូមិផ្សេងៗ ដោយប្តូរគ្នាល្បាតប្រចាំថ្ងៃ) ។ អ្នកនេសាទល្មើសច្បាប់ ត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅស្ថាប័នសមស្របនៅមូលដ្ឋាន ។

សហគមន៍បានបោះបង្គោលព្រំដែននេសាទរបស់ខ្លួន រួមទាំងដាក់ផ្លាកសញ្ញាសំរាប់អប់រំ និងណែនាំប្រជាពលរដ្ឋឱ្យថែរក្សាធនធាន ។ សហគមន៍ មូលដ្ឋានបានកត់សំគាល់ថា ធនធានបានកើនឡើងវិញ ៦០% ។ ឧទាហរណ៍ គ្រួសារទាំងឡាយបានកត់សំគាល់ថាពួកគេធ្លាប់តែនេសាទរៀវបានត្រឹម ២គ.ក/ថ្ងៃ បច្ចុប្បន្ន ពួកគេអាចនេសាទបានរហូតដល់ ៥គ.ក/ថ្ងៃ ។ ទន្ទឹមនឹងការអនុវត្តច្បាប់បានតឹងរ៉ឹង ប្រឆាំងនឹងការនេសាទខុសច្បាប់ ប្រជាពលរដ្ឋភាគច្រើន បានប្តូរទៅប្រើប្រាស់ឧបករណ៍នេសាទតាមបែបបុរាណវិញ ។

## សំនួរណែនាំសំរាប់អ្នកសំរបសំរួលៈ

1. តើអ្នកមានយោបល់យ៉ាងណាចំពោះ ករណីសិក្សាដែលបានបង្ហាញជូន ?
2. ហេតុអ្វីការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងជលផលមានសារៈសំខាន់ ?
3. ក្នុងតំបន់ដែលអ្នករស់នៅ តើអ្នកពិនិត្យឃើញមានការគ្រប់គ្រងបែបនេះដែរឬទេ ?
4. តើអ្នកយល់យ៉ាងណាអំពីការគ្រប់គ្រងបែបនេះ ?

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួលៈ

ការបង្ហាញអំពីករណីសិក្សា គឺជាគោលបំណងដើម្បីពិភាក្សាបទពិសោធន៍ជាក់លាក់ទាក់ទងនឹងការគ្រប់គ្រងសហគមន៍នេសាទ និងដកស្រង់យកគំនិតល្អៗ ទាក់ទងនឹងការគ្រប់គ្រង និងការចូលរួម ។ ក្នុងករណីសមស្រប អ្នកសំរបសំរួលអាចស្នើឱ្យសិក្ខាកាមមួយចំនួន ធ្វើបទបង្ហាញឱ្យបានខ្លីៗអំពីបទពិសោធន៍របស់ខ្លួន ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។ ចូរកត់សំគាល់នូវដំណាក់កាលខុសគ្នាខ្លះៗក្នុងការគ្រប់គ្រងជលផល ។ នៅចុងបញ្ចប់នៃការពិភាក្សា អ្នកសំរបសំរួលគួរតែធ្វើសេចក្តីសង្ខេបអំពីករណីសិក្សាទាំងនេះ និងឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការចូលរួមក្នុងការគ្រប់គ្រងធនធាន ។

## ចំណាក់កាលជាគន្លឹះក្នុងការគ្រប់គ្រងសហគមន៍នេសាទ

មានវិធីជាច្រើនសំរាប់រៀបចំសហគមន៍នេសាទ ឬគ្រប់គ្រងធនធានសហគមន៍ ប៉ុន្តែក៏មានចំនុចជាច្រើនដែរ ដែលចាំបាច់ត្រូវពិចារណា ។ ខាងក្រោមនេះ គឺជាចំនុចដែលអ្នកសំរបសំរួលគួរពិចារណាក្នុងពេលចាត់ចែងបង្កើតសហគមន៍នេសាទ រឺក៏សហគមន៍គ្រប់គ្រងធនធានដ៏ទៃទៀត។ ត្រូវចងចាំថា នេះគ្រាន់តែជាគោលការណ៍ណែនាំតែប៉ុណ្ណោះ ។

- អ្នកសំរបសំរួលចាំបាច់ត្រូវយល់ឱ្យបានច្បាស់ពីដែលខ្លួនត្រូវជាមួយសហគមន៍ ពោលគឺកំណត់ឱ្យបានច្បាស់គឺគោលបំណង ។

- ក្នុងកិច្ចដំណើរការបង្កើតសហគមន៍ នៅមុន រឺក្រោយគណៈកម្មការសហគមន៍ត្រូវបានបង្កើតឡើង ចាំបាច់ត្រូវសុំការគាំទ្រពីអាជ្ញាធរខេត្ត និងបណ្តាមន្ទីរពាក់ព័ន្ធ ពោលគឺការិយាល័យជលផល ឬមន្ទីរបរិស្ថានក្នុងករណីតំបន់ដែលត្រូវរៀបចំស្ថិតនៅក្នុងបរិវេណតំបន់ការពារធម្មជាតិ ។
- កំនត់មនុស្សសំខាន់ៗក្នុងភូមិ ហើយចំណាយពេលដើម្បីពិភាក្សាអំពីការគ្រប់គ្រងជលផលក្នុងភូមិ ។ ជាមួយគ្នានេះដែរ រៀបចំទស្សនៈកិច្ចសិក្សាទៅបណ្តាលភូមិដទៃទៀតដែលបានរៀបចំសហគមន៍នេសាទមុន ។
- ធ្វើការជាមួយនឹងមនុស្សសំខាន់ៗក្នុងភូមិ ដើម្បីបើកវគ្គបណ្តុះបណ្តាលទូទៅស្តីពីទស្សនទាននៃសហគ្រប់គ្រងធនធានធម្មជាតិដែលមានការចូលរួមពីសហគមន៍។
- ផ្តល់លទ្ធភាពឱ្យសហគមន៍ធ្វើការសំរេចចិត្ត ប្រសិនបើគេមានការចាប់អារម្មណ៏ពីការគ្រប់គ្រងធនធានធម្មជាតិ ។ បើសិនជាពួកគេចង់ធ្វើការគ្រប់គ្រង តើអ្វីខ្លះដែលត្រូវគ្រប់គ្រង ? ធនធាននេសាទ រឺក៏អ្វីផ្សេងៗទៀតដូចជាៈ ការរកអុស ដុត ការផលិតធ្យូង និងការប្រើប្រាស់ទឹកជាដើម ។
- រៀបចំជាក្រុមបណ្តាអ្នកស្ម័គ្រចិត្តចូលសហគមន៍ បង្កើតគណៈកម្មការគ្រប់គ្រងធនធាន
- គាក់តែងលក្ខន្តិកៈនិងបទបញ្ញាតិសំរាប់គ្រប់គ្រងធនធាន
- ឱ្យសហគមន៍សំរេចកំនត់អំពីតំបន់ ដែលពួកគេចង់គ្រប់គ្រង
- ស្វែងរកការឯកភាពនិងទទួលស្គាល់ លក្ខន្តិកៈ បទបញ្ញាតិ និងព្រំប្រទល់ពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ ។
- ផ្សព្វផ្សាយ លក្ខន្តិកៈនិងបទបញ្ញាតិដែលបានទទួលស្គាល់ហើយ
- បោះបង្គោលកំនត់ព្រំប្រទល់តំបន់គ្រប់គ្រងដោយសហគមន៍
- អនុវត្ត( ត្រូវការពេលវេលា និងការសំរបសំរួលឱ្យបានល្អ ដើម្បីធ្វើការសំរេចចិត្តនូវយុទ្ធសាស្ត្រនានាសំរាប់អនុវត្តបទបញ្ញាតិ ដែលបានគាក់តែង)

- ❑ តាមដាន ត្រួតពិនិត្យលើសកម្មភាពមួយចំនួនដូចជា ការដាំដើមឈើ ការអនុវត្តបទបញ្ញាតិ សកម្មភាពអប់រំ (គួរឱ្យសហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការនេះ)
- ❑ ល្បាតត្រួតពិនិត្យសកម្មភាពល្មើសក្នុងដែនសហគមន៍គ្រប់គ្រង
- ❑ វាយតំលៃ និងកែសំរួល

**ករណីសិក្សាអំពីការគ្រប់គ្រងសហគមន៍នេសាទបានស្នើថា**

- ❑ ការប្រើប្រាស់ពហុយុទ្ធសាស្ត្រមានសារៈសំខាន់ណាស់ ។ យុទ្ធសាស្ត្រតែមួយ មិនអាចទទួលជោគជ័យក្នុងការឆ្លើយតបនឹងបញ្ហាស្មុគ្រស្មាញ និងប្លែកៗក្នុងតំបន់ឆ្នេរ និងដែនទឹកសាបបានទេ ។ នៅពេលចងក្រងសហគមន៍ ពោលគឺគណៈកម្មាធិការគ្រប់គ្រងគឺជាចំនុចស្នូលនៃយុទ្ធសាស្ត្រ ការស្រាវជ្រាវ អប់រំ សកម្មភាពគ្រប់គ្រងធនធាន ឯការទ្រទ្រង់ជីវភាពរស់នៅក៏មានសារៈសំខាន់ផងដែរ ។
- ❑ ការចូលរួមនៃសមាជិកសហគមន៍ក្នុងដំណើរការគ្រប់គ្រងមានសារៈសំខាន់ណាស់ ព្រោះថាភាតព្វកិច្ចរបស់ពួកគេនឹងកាន់តែរឹងមាំ ។ ការចូលរួមរបស់សហគមន៍គឺជាគន្លឹះក្នុងការគ្រប់គ្រងធនធានសហគមន៍ ។
- ❑ ការរួមបញ្ចូលស្ត្រីក៏មានសារៈសំខាន់ណាស់ដែរ ។ ដោយសារភាគច្រើនបុរសទៅនេសាទគេងាយនឹងភ្លេចថា ស្ត្រីក៏រួមវិភាគទានផងដែរក្នុងការគ្រប់គ្រងធនធាន ។ ប្រការសំខាន់គឺអ្នកសំរបសំរួលត្រូវកសាងភាពជឿជាក់ក្នុងចំណោមទាំងស្ត្រី និងបុរសនៅក្នុងការងារគ្រប់គ្រងធនធាន ។
- ❑ ការប្រើប្រាស់វិធីនៃការចូលរួមជាឧបករណ៍ស្រាវជ្រាវ នឹងជួយឱ្យប្រជាពលរដ្ឋយល់ពីស្ថានភាពរបស់ពួកគេនៅក្នុងផ្លូវ ដែលមានប្រយោជន៍
- ❑ ជំនួយផ្នែកច្បាប់មានសារៈសំខាន់ណាស់ ។ ការទទួលស្គាល់ផែនការគ្រប់គ្រងជាផ្នែកមួយនៃប្រព័ន្ធច្បាប់ដែលជួយផ្តល់ជាទុន និងជួយឱ្យសហគមន៍មានការទទួលយក ពោលគឺអនុក្រឹត្យស្តីពីការនេសាទ ។

ប្រភព: CBCRM LeaRN, the Philippines

# ផ្នែកទី៥: ការចូលរួម និងការគ្រប់គ្រងសហគមន៍នេសាទ

## លំហាត់ស្តីពីការចូលរួម : ការគូសភ្ជាប់រវាងចំនុចមួយទៅចំនុចមួយ

សកម្មភាពនេះ បង្ហាញពីសេចក្តីត្រូវការឱ្យមានការបំពេញការងារជាក្រុម និងការចូលរួមក្នុងការធ្វើផែនការ ។ សិក្ខាកាមទាំងឡាយត្រូវបានបែងចែកជាពីរ ក្រុម ដែលក្រុមនីមួយៗជ្រើសរើសសមាជិកម្នាក់ឱ្យឈរនៅផ្នែកខាងមុខនៃបន្ទប់ ( អ្នកដែលនៅសល់ឈរនៅផ្នែកខាងក្រោយនៃបន្ទប់) ។ ក្រុមនីមួយៗទទួលយករូបមួយដែលជារូបគំនូរគូរភ្ជាប់រវាងចំនុចមួយទៅចំនុចមួយ ។ ក្រុមទាំងពីរត្រូវប្រាប់ទៅសមាជិករបស់ខ្លួនដែលឈរនៅផ្នែកខាងមុខនៃបន្ទប់នូវពិតមានដែលអាចឱ្យសមាជិករូបនោះគូររូបនៅលើក្តារខៀនបាន ( មិនអនុញ្ញាតឱ្យប្រធានក្រុមទាំងនេះធ្វើសញ្ញាទាក់ទងទៅកាន់ក្រុមរបស់ខ្លួនឡើយ) ។ រយៈពេលសំរាប់គូររូបត្រូវកំណត់ត្រឹម ៥នាទី ។

## សំនួរណែនាំសំរាប់អ្នកសំរបសំរួលដើម្បីឆ្លុះបញ្ចាំងអំពីការគូររូបភ្ជាប់ចំនុចៈ

1. តើសមាជិកក្រុមទាំងអស់បានចូលរួមក្នុងការលេងល្បែងនេះដែរឬទេ ? តើគេចូលរួមបែបណា ?
2. តើអ្នកដឹកនាំក្រុមទទួលបានពិតមានពីក្រុមរបស់គេដែរឬទេ ? ហេតុអ្វី ?
3. តើអ្នកជួបប្រទះការលំបាកអ្វីខ្លះក្នុងការដឹកនាំលេងល្បែងនេះ ? ហេតុអ្វី ?



**កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួលៈ**

នៅក្នុងកិច្ចពិភាក្សា អ្នកសំរបសំរួលអាចបញ្ជាក់ពីការចូលរួម ដែលមិនមែនជាការងាយស្រួល និងក្នុងករណីខ្លះ វាមិនងាយនឹងកើតមានបានឡើយ ។ វាជាការលំបាកណាស់ នៅពេលដែលអ្នកចង់ចូលរួមផ្តល់យោបល់ តែគេមិនប្រគល់តួនាទីនោះដល់អ្នក ។ ពេលដែលយើងគិតអំពីស្ថានភាពជាក់ស្តែង យើងចាំបាច់ត្រូវស្តាប់ពីស្ថានភាពមនុស្សម្នាក់ទៀត ដែលអាចឱ្យយើងសហការការងារបានល្អ ។ ដូចគ្នានេះដែរ ក្នុងជីវភាពជាក់ស្តែង មនុស្សគ្រប់រូបតែងមានយោបល់ ហេតុនេះប្រការចាំបាច់ គឺត្រូវស្តាប់យោបល់របស់សមាជិកទាំងនោះ ។

នៅក្នុងល្បែងនេះ ក៏ដូចជានៅក្នុងស្ថានភាពជាក់ស្តែងដែរ នៅពេលយើងធ្វើការជាមួយគ្នា យើងត្រូវកំនត់តួនាទីរបស់មនុស្សម្នាក់ៗឱ្យបានច្បាស់ ។ យើងត្រូវសួរថា តើនរណាចូលរួមផ្តល់យោបល់ និងនរណាមិនចូលរួមផ្តល់យោបល់ ? ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដំណើរការការងារនៅក្នុងសហគមន៍ ក៏មានសារៈសំខាន់ដូចគ្នានឹងលទ្ធផលចុងក្រោយដែរ ។ ឧទាហរណ៍: សកម្មភាពតួរភ្ជាប់ចំនុចនានា មិនគ្រាន់តែដើម្បីបង្ហាញពី លទ្ធភាពក្នុងការគូររូបនោះប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញពីលទ្ធភាពក្នុងការអនុវត្តន៍តាមការណែនាំ ។ វាជាប្រការសំខាន់ក្នុងការវិភាគលំហាត់ល្បែងពេលនោះបន្ថែមទៀត ប៉ុន្តែវាមិនមែនបង្ហាញពីការចាញ់ឈ្នះនោះទេ ។ យើងអាចចោទសួរខ្លួនឯងថា តើយើងធ្វើការនោះបែបណា ? តើយើងបានធ្វើអ្វីខ្លះ ទើបបានជាយើងអាចឈានដល់ដំណោះស្រាយបែបនេះ ? តើយើងខកខានមិនបានធ្វើអ្វីខ្លះ ? ទាំងដំណើរការ ទាំងលទ្ធផលចុងក្រោយសុទ្ធតែមានសារៈសំខាន់ទាំងអស់ ។

**ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសហគមន៍នេសាទ**

មានសំណួរជាគន្លឹះមួយដែលយើងគួរតែសួរ នៅពេលជជែកអំពីការចូលរួមរបស់សហគមន៍ តើអ្នកណាខ្លះចូលរួម ? ជាការចាំបាច់ អ្នកដែលចូលរួមក្នុងសកម្មភាពរបស់

យើងរួមមាន : ប្រជាពលរដ្ឋ មូលដ្ឋាន អ្នកនេសាទ កសិករ បុរស និងស្ត្រី ក្មេងនិងចាស់ មន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន អ្នកវិទ្យាសាស្ត្រ និស្សិត និង សាស្ត្រាចារ្យ និងអ្នក បង្ហបញ្ហា ។ល។



តើប្រជាពលរដ្ឋចូលរួមធ្វើអ្វី ?

ការធ្វើផែនការ និងអនុវត្តផែនការ កំនត់ផែនការគ្រប់គ្រងធនធាន ផ្តល់ពត៌មានអំពីស្ថានភាពជុំវិញ ចូលជាសមាជិកក្នុងក្រុមស្រាវជ្រាវ ផ្ទៀងផ្ទាត់និងស្វែង រកទិន្នន័យ ពិគ្រោះយោបល់ ប្រមូលពត៌មាន ចូលរួមប្រជុំ ធ្វើការសំរបសំរួល ។ល។

តើយើងផ្លាស់ប្តូរ និងសហការអ្វីខ្លះជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ និងជាមួយអ្នកដទៃទៀត (រដ្ឋាភិបាល ក្រុមស្រាវជ្រាវ ។ល។) ?

| | |
|---|---|
| ❑ ពត៌មាន | ❑ បទពិសោធន៍ |
| ❑ គំនិត | ❑ ការរៀនសូត្រ |
| ❑ ចំណេះដឹង | ❑ សំនួរ/ចំលើយ |
| ❑ ទេពកោសល្យ | ❑ ចំងល់ |
| ❑ រឿងហេតុ | ❑ កង្វល់ |

## លក្ខណៈសម្បត្តិជាមូលដ្ឋានរបស់អ្នកសំរបសំរួល



**អ្នកសំរបសំរួលមានការគោរពចំពោះអ្នកដទៃ**

អ្នកសំរបសំរួលចាំបាច់ត្រូវគោរពទស្សនៈ និងយោបល់របស់មនុស្សគ្រប់រូប ព្រមទាំងលើកទឹកចិត្តឱ្យមានការបញ្ចេញយោបល់គ្រប់គ្នា ។ ការសំរបសំរួលល្អ គឺការអនុញ្ញាតឱ្យប្រជាពលរដ្ឋបង្កើនទេពកោសល្យ និងសមត្ថភាពដោយខ្លួនឯង ។ គួរលើកទឹកចិត្តឱ្យមានការបញ្ចេញទស្សនៈប្លែកៗ ។

### អ្នកសំរបសំរួលប្រកាន់ឥរិយាបទទទ់ភ្ជន់ចំពោះទំនៀមទំលាប់មូលដ្ឋាន

នេះមានន័យថា អ្នកសំរបសំរួលគួរមានការគោរពជាមូលដ្ឋានចំពោះទំនៀមទំលាប់របស់ប្រជាពលរដ្ឋដែលខ្លួនធ្វើការជាមួយ ។ អ្នកសំរបសំរួលអាចព្យាយាមស្វែងយល់អំពីព្រឹត្តិការណ៍ និងស្ថានភាពទៅតាមទស្សនៈរបស់សហគមន៍ និងអាចសំរបខ្លួនទៅតាមទិដ្ឋភាពជាវិជ្ជមាននៃរបៀបរស់នៅ ទេពកោសល្យ បច្ចេកវិទ្យា ប្រពៃណី ជំនឿ និងទំនៀមទំលាប់របស់គាត់ ។

### អ្នកសំរបសំរួលប្រកាន់សិទ្ធិស្មើភាពរវាងបុរស និងស្ត្រី

អ្នកសំរបសំរួលដែលមិនប្រកាន់ភេទត្រូវចាប់អារម្មណ៍លើការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបុរស ពោលគឺ រាល់ការពិចារណាហេតុការណ៍នានា ត្រូវផ្អែកលើទស្សនៈរបស់ភេទទាំងពីរ ។ ឧទាហរណ៍ : អ្នកសំរបសំរួលត្រូវធ្វើឱ្យសហគមន៍គាំទ្រទស្សនៈ ទទួលស្គាល់សារៈសំខាន់ និងតួនាទីរបស់ស្ត្រី ហើយស្ត្រីក៏មានតួនាទីសំខាន់ក្នុងការគ្រប់គ្រងធនធានរបស់សហគមន៍ ។

### អ្នកសំរបសំរួលយកចិត្តទុកដាក់ចំពោះបរិស្ថាន

អ្នកសំរបសំរួលចាំបាច់ត្រូវបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន ។ មនុស្សនិងបរិស្ថានមានទំនាក់ទំនងគ្នាជិតស្និទ្ធ ហើយយើងមិនអាចសំរេចបាននូវការអភិវឌ្ឍន៍ដោយនិរន្តរភាព ដោយពុំគិតពីកិច្ចការពារបរិស្ថានបានឡើយ ។

## ផ្នែកទី៦: ការធ្វើផែនការសំរាប់ការចូលរួមគ្រប់គ្រងធនធាន

### លំហាត់ស្តីពីការចូលរួមដោះស្រាយបញ្ហា :

លំហាត់ដោះស្រាយបញ្ហា គឺជាសកម្មភាពបង្ហាញថា ក្រុមទាំងឡាយរួមគ្នាដោះស្រាយបញ្ហារបស់ខ្លួន ប្រសើរជាងឱ្យអ្នកមកពីក្រៅ "ផ្តល់ដំណោះស្រាយ" ។ ជាបឋមគេជ្រើសរើសសិក្ខាកាម២ រឺ៣នាក់ ឱ្យចេញទៅក្រៅថ្នាក់រៀន ។ បន្ទាប់មក អ្នកសំរបសំរួលស្នើឱ្យអ្នកដែលនៅសល់ក្នុងថ្នាក់ ឈរកាន់ដៃគ្នាជារង្វង់ ហើយដោយមិនឱ្យលែងដៃពីគ្នា ពួកគេត្រូវឆ្លាស់គ្នារបៀបដូចជាខ្សែចំណងដែលជំពាក់ ។ រួចរាល់ហើយ អ្នកសំរបសំរួលស្នើឱ្យអ្នកដែលចេញទៅក្រៅនោះចូលមកវិញដើម្បីស្រាយចំណងនេះ ។ មានលក្ខខ័ណ្ឌខ្លះចំពោះការស្រាយនេះ គឺថាហាមប៉ះពាល់ចំណង( អ្នកដែលឈរ) និងមិនត្រូវឱ្យពួកគេលែងដៃពីគ្នាទេ តែអាចនិយាយឆ្លើយឆ្លងជាមួយពួកគេបាន ។ មានពេលតែ៣ រឺ ៤ នាទីប៉ុណ្ណោះសំរាប់ការស្រាយចំណងនេះ ហើយប្រសិនបើពួកគេមិនអាចស្រាយបាន



អ្នកសំរបសំរួលស្នើឱ្យអ្នកដែលនៅជាចំណងនេះ ស្រាយដោយខ្លួនឯងម្តង ដោយហាមលែងដៃគ្នាពេលកំពុងស្រាយ ។



## សំនួរណែនាំសំរាប់អ្នកសំរបសំរួល:

1. ហេតុអ្វីអ្នកដោះស្រាយបញ្ហា មិនអាចបំបែកសមាជិកក្រុមចេញពីគ្នាបាន ?
2. ហេតុអ្វីបានជាសមាជិកក្រុមអាចបំបែកចេញពីគ្នាដោយខ្លួនឯងយ៉ាងងាយស្រួល ?
3. តើល្បែងនេះ ឆ្លុះបញ្ចាំងស្ថានភាពជាក់ស្តែងយ៉ាងដូចម្តេច ?

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួល

អ្នកសំរបសំរួល អាចលើកទឹកចិត្តឱ្យមានការពិភាក្សាអំពីទំនាក់ទំនងរវាងល្បែងនេះជាមួយស្ថានភាពនៃការរស់នៅជាក់ស្តែង ។ ល្បែងនេះអាចបង្ហាញឱ្យឃើញថា សហគមន៍ស្គាល់បញ្ហារបស់ខ្លួនបានច្បាស់ជាងអ្នកមកពីក្រៅ ជាពិសេស អាចបណ្តុះគំនិតប្រជាពលរដ្ឋឱ្យមានការគិតគូរពីស្ថានភាពរបស់ខ្លួនផ្ទាល់ ។ ប៉ុន្តែអ្នកមកពីក្រៅក៏នៅតែមាននាទីផងដែរនៅក្នុងស្ថានភាពជាក់ស្តែង ។ នៅពេលដែលសហគមន៍ចង់ដឹងពីវិធីដោះស្រាយបញ្ហារបស់ខ្លួន

អ្នកមកពីក្រៅអាចមានចំណែកជា "អ្នកជំរុញ" ឬក៏អ្នកដែលបណ្តុះគំនិតឱ្យប្រជាពលរដ្ឋធ្វើការរួមគ្នា ។ អ្នកដោះស្រាយបញ្ហាដែលជាអ្នកមកពីក្រៅ ក៏អាចជួយសហគមន៍ឱ្យយល់បន្ថែមទៀតអំពីប្រភេទនៃបញ្ហា ។ បញ្ហាចាប់ផ្តើមមាន នៅពេលដែលអ្នកមកពីក្រៅមិនបានពិគ្រោះយោបល់ជាមួយសហគមន៍ ក្នុងពេលព្យាយាមដោះស្រាយបញ្ហាសហគមន៍ ។

## ផ្នែកទី៧ : ការពិចារណាអំពីការគ្រប់គ្រងសហគមន៍នេសាទ ក្នុងប្រទេសកម្ពុជា

មុននឹងបរិយាយបន្ថែមទៀត អំពីការធ្វើផែនការសំរាប់ការចូលរួមគ្រប់គ្រងធនធាន យើងស្នើឱ្យមានការពិភាក្សាអំពីការគ្រប់គ្រងសហគមន៍នេសាទក្នុងបរិបទប្រទេសកម្ពុជា ។ អង្គការ និងស្ថាប័នរដ្ឋាភិបាលអាចសួរខ្លួនឯងតាមសំណួរណែនាំមួយចំនួនដូចខាងក្រោម :

1. តើអ្វីខ្លះជាចំណុចសំខាន់សំរាប់ពិចារណានៅពេលចាប់ផ្តើមរៀបចំសហគមន៍នេសាទ ?
   - តើយើងគួរពិចារណារឿងរ៉ាវអ្វីខ្លះ ?
   - តើយើងគួរធ្វើទំនាក់ទំនងជាមួយស្ថាប័នណាខ្លះ ?
   - តើយើងគួរជជែកជាមួយអ្នកណាខ្លះនៅក្នុងសហគមន៍ ?
   - តើយើងអាចធ្វើបែបណា ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋជឿថា យើងជាអ្នកសំរបសំរួល ?
2. តើយើងចាំបាច់ត្រូវពិចារណាលើកត្តាអ្វីខ្លះ (នៅក្រៅសហគមន៍) ដែលនឹងជះឥទ្ធិពលដល់ការងាររបស់យើង ?
   - តើមានគោលនយោបាយជាតិ ឬអន្តរជាតិ ឬច្បាប់អ្វីខ្លះដែលជះឥទ្ធិពលដល់សហគមន៍ ? តើវាមានឥទ្ធិពលបែបណា ?

- ❑ តើប្រព័ន្ធចរាចរទំនិញ ឬពាណិជ្ជកម្មធនធានប្រព្រឹត្តទៅបែបណា ? អ្នកណាជាអ្នកត្រួតត្រា ?
- ❑ តើមានអ្នកណាផ្សេងទៀតក្រៅពីសហគមន៍ដែលប្រើប្រាស់ធនធានជលផល ?

3. តើយើងមានបទពិសោធន៍ និងចំណេះដឹងអ្វីខ្លះសំរាប់ជួយរៀបចំសហគមន៍នេសាទ ?
4. តើយើងត្រូវការបទពិសោធន៍ និងចំណេះដឹងអ្វីខ្លះជាបន្ថែមសំរាប់រៀបចំសហគមន៍ ?

**ឧទាហរណ៍: ការពិចារណាអំពីការគ្រប់គ្រងសហគមន៍នេសាទក្នុងខេត្តកោះកុង ប្រទេសកម្ពុជា**

| | |
|---|---|
| **ចំនុចគួរពិចារណាអំពីការគ្រប់គ្រងសហគមន៍នេសាទ** | ការប្រតិបត្តិដែលទាក់ទងជាមួយការគ្រប់គ្រងសហគមន៍នេសាទរួមមាន:<br>1. ការជ្រើសរើសទីតាំង<br>2. ការសង្កេតអំពីស្ថានភាពមូលដ្ឋាន ( របៀបធ្វើការងារ និងរបៀបរស់នៅ)<br>3. ការប្រជុំនៅមូលដ្ឋានដើម្បីពិភាក្សារៀបចំរចនាសម្ព័ន្ធសហគមន៍នេសាទ<br>4. ការបង្កើតបទបញ្ជាជាមួយសហគមន៍សំរាប់សហគមន៍នេសាទ<br>5. ការធ្វើផែនការគ្រប់គ្រងជាមួយសហគមន៍<br>6. ការអនុវត្តន៍ផែនការ និងការវាយតំលៃ<br>- ប្រការសំខាន់ គឺត្រូវដោះស្រាយទំនាស់នៃការនេសាទ ពោលគឺរវាងអ្នកនេសាទទ្រង់ទ្រាយធំ និងអ្នកនេសាទតូចតាច ។<br>- តើអ្នកអាចធានានិរន្តរភាពជីវភាពរស់នៅសំរាប់សហគមន៍ដោយរបៀបណា ?<br>- គួរតែនិរមានការចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋាន ដូចជាមន្ទីរ |

| | |
|---|---|
| | បរិស្ថាន ការិយាល័យជលផល មន្ទីរអភិវឌ្ឍន៍ជនបទ និងកិច្ចការនារីដែរឬទេ ? ហើយអង្គការក្រៅរដ្ឋាភិបាល គួរតែឱ្យចូលរួមផងដែរឬ ?<br>- តួនាទីរបស់គំរោងស្តីពីការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង គឺដើម្បីជួយទ្រទ្រង់សហគមន៍ ។ គំរោងនេះចូលរួម និងជួយដោះស្រាយប្រជាពលរដ្ឋមូលដ្ឋាននៅពេលពួកគាត់មានបញ្ហា ដោយជួយស្វែងរកជំរើសសមស្របបំផុតសំរាប់ពួកគាត់ ។ |
| កត្តាពីខាងក្រៅដែលជះឥទ្ធិពលដល់សហគមន៍ | - ទូកនេសាទបរទេសធ្វើនេសាទនៅក្បែរសហគមន៍ ( ជាពិសេស ទូកនេសាទថៃ) ដោយមានកំលាំងប្រដាប់អាវុធការពារ ។<br>- ច្បាប់ជាតិជះឥទ្ធិពលដល់ជីវភាពរបស់សហគមន៍ ពោលគឺគោលនយោបាយហាមឃាត់ការផលិតធ្យូង ។<br>- ការនេសាទខុសច្បាប់នៅជិតព្រំប្រទល់ប្រទេសកម្ពុជា-ថៃ ។ |
| បទពិសោធន៍ ចំណេះដឹងនិងឥរិយាបទដែលមានបច្ចុប្បន្ន | - បទពិសោធន៍ និងចំណេះដឹងដើម្បីជួយសំរបសំរួល និងបង្កើតសហគមន៍នេសាទ ។<br>- បទពិសោធន៍ផ្នែកបច្ចេកទេសនេសាទ ។<br>- បទពិសោធន៍ខាងផ្នែកបរិស្ថាន<br>- ឥរិយាបទផ្លាស់ប្តូរតាមសភាពការណ៍ ។ |

# ផ្នែកទី៨ : មធ្យោបាយសំរាប់ការធ្វើផែនការគ្រប់គ្រងធនធាន ដោយមានការចូលរួម

## ការធ្វើផែនការសំរាប់ការចូលរួមគ្រប់គ្រងធនធាន

ការគ្រប់គ្រងធនធានជលផលដោយសហគមន៍ គឺជាផ្នែកមួយនៃការធ្វើផែនការ គ្រប់គ្រង ។ ក្រោយពេលដែលសហគមន៍មានទំនុកចិត្ត និងអ្នកសំរបសំរួលហើយ ការធ្វើផែនការ គ្រប់គ្រងត្រូវចាប់ផ្តើមដំណើរការ ។

ខាងក្រោមជាវិធីសាស្ត្រមួយចំនួនសំរាប់ធ្វើផែនការគ្រប់គ្រងធនធាន :

1. ការកំណត់ និងវិភាគបញ្ហា
2. ការវិភាគភាគីពាក់ព័ន្ធ
3. ការកំនត់គោលដៅ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព
4. បង្កើតគន្លាចង្អុលបង្ហាញ
5. ផែនការសកម្មភាព

ការធ្វើផែនការគ្រប់គ្រងគឺផ្តល់លទ្ធភាពឱ្យបណ្តាអ្នកពាក់ព័ន្ធកំនត់បញ្ហានិងយុទ្ធសាស្ត្រនានាសំរាប់ដោះស្រាយបញ្ហា ។ វាពិបាកនឹងទទួលបានលទ្ធផលល្អ ប្រសិនបើគោលលំនាំខាងលើមិនត្រូវបានយកមកអនុវត្តក្នុងការធ្វើផែនការទេ ។ ធ្វើផែនការ ត្រូវបត់បែនទៅតាមកាលៈទេសៈ និងប្រើសំរាប់ជួយយើងក្នុងការដោះស្រាយបញ្ហា ។ វិធីសាស្ត្រធ្វើផែនការដែលបានបង្ហាញខាងលើ គឺជាយុទ្ធសាស្ត្រមួយក្នុងបណ្តាយុទ្ធសាស្ត្រជាច្រើនទៀតសំរាប់គ្រប់គ្រងធនធានជលផល ។

## ការកំណត់ និងវិភាគបញ្ហា

ការកំណត់ និងវិភាគបញ្ហា អាចឱ្យអ្នកសំរបសំរួលធ្វើការជាមួយសហគមន៍ក្នុងការកំណត់និយមន័យ វិភាគ កំណត់អាទិភាពនៃបញ្ហា និងសេចក្តីត្រូវការរបស់សហគមន៍ ។ កិច្ចការនេះអាចធ្វើទៅបានអាស្រ័យទៅតាមសារៈសំខាន់ ភាពបន្ទាន់ដែលត្រូវដោះស្រាយបញ្ហាមួយចំនួនដែលប្រជាពលរដ្ឋដែលជួបប្រទះ និងលទ្ធភាពនៃការដោះស្រាយបញ្ហាតាមរយៈសកម្មភាពរបស់សហគមន៍ ។

ការចរចារកត់និតថ្មីជាមួយសហគមន៍ និងកត់ត្រាបញ្ហាទាំងឡាយរបស់សហគមន៍ រួមទាំងបណ្តាបញ្ហាដែលជាប់ទាក់ទង និងមិនជាប់ទាក់ទង :

## សំនួរណែនាំសំរាប់អ្នកសំរបសំរួល

- ⇨ តើអ្នកណាខ្លះជួបបញ្ហា ?
- ⇨ តើមានប្រជាពលរដ្ឋប៉ុន្មាននាក់ដែលជួបបញ្ហា ? តើមានបញ្ហាដូចម្តេច ?
- ⇨ តើបញ្ហានេះបង្កផលវិបាកដល់សហគមន៍បែបណា ?
- ⇨ តើសមាជិកសហគមន៍ម្នាក់ៗមានអារម្មណ៍ដោយឡែកពីគ្នាបែបណា និងដូចគ្នាបែបណា ?
- ⇨ តើបញ្ហាណាមួយត្រូវការដោះស្រាយបន្ទាន់ ?
- ⇨ តើបញ្ហាណាមួយដែលងាយស្រួលនឹងអាចសាកល្បងដោះស្រាយបាន ដោយផ្អែកលើធនធានដែលសហគមន៍មាន ?

នៅពេលធ្វើការកំណត់បញ្ហារបស់សហគមន៍ ត្រូវស្តាប់យោបល់ពីសហគមន៍ ( ត្រូវចាំថា សហគមន៍ដឹងពីបញ្ហារបស់ពួកគាត់) ។ ត្រូវគិតពីសមត្ថភាពរបស់ខ្លួន ក្នុងនាមជាអ្នកសំរបសំរួល និងគិតពីបញ្ហាដែលត្រូវដោះស្រាយមុនគេ ។ ឧទាហរណ៍ : ការនេសាទត្រីក្នុងដែនទឹកកម្ពុជាដោយទូកនេសាទធំៗមកពីប្រទេសថៃគឺជាបញ្ហាធំ ។ ក្នុងនាមជាអ្នក

សំរបសំរួលពីការគ្រប់គ្រងជលផល តើយើងគួរចាប់ផ្តើមដោះស្រាយបញ្ហានេះឥឡូវឬយ៉ាងណា ? តើយើងមានសមត្ថភាពជួយសហគមន៍ដោះស្រាយបញ្ហានេះដែរឬទេ ? ឬមួយយើងគិតអំពីបញ្ហាផ្សេងសំរាប់ដោះស្រាយ ? នេះមិនមែនមានន័យថា យើងមិនចង់ដោះស្រាយបញ្ហាខាងលើនេះទេ ប៉ុន្តែយើងត្រូវមានភាពស្មោះត្រង់ និងប្រាកដនិយមអំពីអ្វីដែលយើងអាចធ្វើបាន ។

អ្នកសំរបសំរួលអាចកំណត់បញ្ហា ដោយផ្អែកលើចំនុចបីខាងក្រោម :

⇨ តើអ្វីខ្លះមានសារៈសំខាន់ចំពោះសហគមន៍ ?

⇨ តើយើងអាចរកផ្លូវដោះស្រាយបញ្ហានោះនៅពេលបច្ចុប្បន្នបានដែរឬទេ ?

⇨ ពិនិត្យមើលដំនើរការ ។ តើយើងកត់សំគាល់បញ្ហាដោយរបៀបណា ?

## ឧទាហរណ៍: ការកត់សំគាល់ និងវិភាគបញ្ហានៅឧទ្យានជាតិរាម ប្រទេសកម្ពុជា

**បញ្ហា**

1. ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ ពោលគឺ អួនអូស និងឈើបយន្តនៅតំបន់ទឹករាក់ ។
2. ការកាប់ព្រៃកោងកាងធ្វើកសិដ្ឋានចិញ្ចឹមបង្គារ និងក្តាម ផលិតធ្យូង និងឈើធ្វើបង្គោល ។
3. រាំងព្រួល រួមផ្សំនឹងសំណាញ់ រាំងស្ទះចរន្តទឹកហូរនៅតាមស្ទឹងនានា ។
4. ការនេសាទដោយទូកនេសាទមកពីបរទេស គាំទ្រដោយមនុស្សមួយចំនួនដែលមានអំណាច ។

**ទំនាក់ទំនង**

1. ការប្រើឧបករណ៍នេសាទខុសច្បាប់ជះឥទ្ធិពលអាក្រក់ដល់អ្នកនេសាទតូចតាច ពោលគឺធ្វើឱ្យបាត់បង់ត្រី និងបង្កទំនាស់ ។
2. កាប់ព្រៃកោងកាងជាការបំផ្លាញធនធានធម្មជាតិ បំពុលបរិស្ថាន ធ្វើឱ្យបាត់បង់ជំរកត្រី និងសត្វស្លាប ធ្វើឱ្យហូរច្រោះ និងបង្កផលវិបាកដល់ប្រជាពលរដ្ឋដែលនេសាទត្រីក្នុងព្រៃកោងកាង ។

| |
|---|
| 3. ការរាំងព្រួលនាំឱ្យស៊ឹងកាន់តែរាក់ ជាហេតុនាំឱ្យមានទឹកជំនន់នៅរដូវភ្លៀង និងបង្កផលវិបាកដល់ការបន្តពូជរបស់ត្រី ។ ស្មៅដែលច្រូតនៅរដូវប្រាំងត្រូវជាប់នឹងព្រួលនេះ មានន័យថាទឹកមិនអាចហូរបាន ជាហេតុនាំឱ្យដីស្រែត្រូវលិចលង់ ។ ប្រជាពលរដ្ឋដែលចិញ្ចឹមទៀវបាត់បង់កន្លែងរបស់ខ្លួន ។<br>4. ការនេសាទដោយទូកបរទេសបង្កទំនាស់ជាមួយអ្នកនេសាទក្នុងស្រុក ពេលគឺទំនាស់ក្នុងការប្រើប្រាស់ដែននេសាទ ។ |
| ចំណុចចំបងត្រូវពិចារណា<br>1. ការអនុវត្តច្បាប់មានសភាពធូររលុង ។<br>2. ប្រជាពលរដ្ឋដែលមានឡដុតធ្យូងបានធ្វើតាំងពីបុរាណសំមកហើយ ហើយប្រសិនបើអ្នកចង់បញ្ឈប់សកម្មភាពនេះ អ្នកត្រូវរកជំរើសផ្សេងសំរាប់ពួកគាត់ ។<br>4. អ្នកមានអំណាចមួយចំនួនការពារសកម្មភាពល្មើសច្បាប់ ។ |

## កំនត់សំគាល់បន្ថែមសំរាប់អ្នកសំរបសំរួល

ការយកចិត្តទុកដាក់ចំពោះបញ្ហាទាំងនេះ គួរតែចាត់ចែងក្រោមរូបភាពជាក់លាក់ និងច្បាស់លាស់ ។ ឧទាហរណ៍ ៖ ប្រសិនបើការនេសាទដោយអួនអូសគឺជាបញ្ហា មានតែប្រជាពលរដ្ឋដែលធ្វើនេសាទនៅតំបន់ឆ្នេរទេដែលយល់ច្បាស់ពីបញ្ហានេះ ប៉ុន្តែប្រជាពលរដ្ឋនៅតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជាអាចមិនយល់ថាប្រការនេះជាបញ្ហា ។ ត្រូវរៀបចំបង្ហាញបញ្ហានេះឡើងវិញ ដើម្បីបញ្ជាក់ពីទីកន្លែងដែលមានបញ្ហានេះ តើអ្នកណាខ្លះរងគ្រោះ ឬអ្វីខ្លះជាផលវិបាកពីបញ្ហានេះ ។ អ្នកសំរបសំរួលអាចបញ្ជាក់ថា "ការពិចារណាចំបង" មិនមែនជាដំណោះស្រាយចំពោះបញ្ហានេះទេ ប៉ុន្តែវាជាគំនិតដែលអាចនាំទៅរកដំណោះស្រាយ ។ ឧទាហរណ៍ ៖ ប្រសិនបើការនេសាទដោយឧបករណ៍ផ្សងផាង គឺជាបញ្ហា ក្នុងករណីនេះការពិចារណាត្រូវរួមបញ្ចូលប្រការដែលថា មានពិតមានតិចតួចប៉ុណ្ណោះ ស្តីពីផលប៉ះពាល់

ចំពោះធនធានជលផលបណ្ដាលពីការនេសាទដោយផ្ទួងផ្ដាង ។ ការពិចារណា ជួយតំរង់ទិស អ្នកសំរបសំរួល និងសហគមន៍កំណត់សកម្មភាពឈានទៅរកដំណោះស្រាយ ។

**ការវិភាគអំពីភាគីពាក់ព័ន្ធ**

ការវិភាគភាគីពាក់ព័ន្ធលើបញ្ហាមួយ អាស្រ័យនឹង:

- ❑ អាយុ និងភេទ
- ❑ សាសនា
- ❑ គណៈបក្សនយោបាយ
- ❑ មុខរបរ
- ❑ បទពិសោធន៍
- ❑ កំរិតវប្បធម៌
- ❑ គ្រួសារ និងញាតិសណ្ដាន
- ❑ ទីតាំងភូមិសាស្ត្រ ។ល។

ភាគីពាក់ព័ន្ធមួយ គឺជាបុគ្គលម្នាក់ ឬជាក្រុមមនុស្សមួយក្រុម ដែលអាចមានទំនាក់ទំនងនឹងសកម្មភាព ឬបញ្ហាជាក់លាក់ណាមួយ ។ ឧទាហរណ៍: ការនេសាទ គឺជាសកម្មភាពមួយដែលចាំបាច់សំរាប់អ្នកនេសាទ ពីព្រោះវាទាក់ទងនឹងការចិញ្ចឹមជីវិតរបស់ពួកគាត់ ។ ជាមួយគ្នានេះ ឈ្មួញកណ្ដាលក៏ពាក់ពន្ធ័ជាមួយការនេសាទដែរ ពីព្រោះពួកគេត្រូវការទិញផលនេសាទ ។ រីឯរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក៏ពាក់ពន្ធ័ និងចាប់អារម្មណ៍ក្នុងការនេសាទដែរ ពីព្រោះ ពួកគេចង់ឱ្យបណ្ដាអ្នកនេសាទមានមុខរបរចិញ្ចឹមជីវិត ហើយពួកគេក៏បរិភោគត្រីដែរ ។

ដើម្បីធ្វើការវិភាគអំពីភាគីពាក់ព័ន្ធ ត្រូវកត់ត្រារាល់ភាគីពាក់ព័ន្ធទាំងអស់ ហើយបន្ទាប់មក បញ្ជាក់ពីទំនាក់ទំនងភាគីទាំងនោះទៅនឹងបញ្ហាដែលលើកយកមកពិភាក្សា ។ បន្ទាប់មកទៀត កំណត់ថាតើភាគីណាមិនបង្កើតឱ្យមានបញ្ហា ភាគីណាធ្វើឱ្យមានបញ្ហា និង ភាគីណាមិនទាក់ទង ។

## ឧទាហរណ៍: ការវិភាគភាគីពាក់ព័ន្ធនៅខេត្តកោះកុង

**បញ្ហា: ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជាឈើបយន្ត និងអួនអូសនៅជ្រោយប្រស់**

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង និងការអធិប្បាយ | ដំណោះស្រាយ | | |
|---|---|---|---|---|
| | | គ្មានបញ្ហា | មានបញ្ហា | គ្មានទាក់ទង |
| - អ្នកនេសាទខុសច្បាប់ | - គ្មានមុខរបរផ្សេង ប៉ុន្តែគេអាចប្តូរឧបករណ៍ប្រើប្រាស់បាន | | * | |
| - អ្នកនេសាទប្រើឧបករណ៍ផ្សេងៗ | - អ្នកខ្លះត្រូវបានរៀបចំ និងបង្កើតជាក្រុម និងមានការយល់ដឹងអំពីការខូចខាតធនធាន និងបរិស្ថាន | * | | |
| - ឈ្មួញកណ្តាល | - ទទួលប្រយោជន៍ពីការទិញ និងលក់ត្រី ដែលបានពីការនេសាទដោយឈើបយន្ត និងអួនអូស | | * | |
| - អាជ្ញាធរមូលដ្ឋាន | - ពុំមានធនធានគ្រប់គ្រាន់សំរាប់ពង្រឹងការអនុវត្តន៍ច្បាប់ ។ | * | | |

## ការកំណត់គោលដៅ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព

**តើមានគោលការណ៍ណែនាំណាខ្លះ សំរាប់កំណត់គោលដៅ និងគោលបំណង ?**

- គោលបំណងគួរតែអាចសំរេចបាន ។
- គោលបំណងគួរតែបំរើផលប្រយោជន៍ប្រជាពលរដ្ឋភាគច្រើននៅក្នុងតំបន់ ។

**គោលដៅ**

កំណត់នូវទិសដៅទូទៅអំពីអ្វីដែលគួរធ្វើ សំរាប់ចន្លោះពេលជាក់លាក់មួយ ។

**គោលបំណង**

គឺជាបំណងជាក់លាក់ ដែលចាំបាច់ត្រូវបំពេញ ដើម្បី សំរេចគោលដៅ ។

- ❑ គោលបំណងអាចប្រែប្រួលតាមកាលៈទេសៈ ។
- ❑ គោលបំណងគួរតែមានការពាក់ព័ន្ធនឹងសហគមន៍ ។

☞ យុទ្ធសាស្ត្រគឺជាមធ្យោបាយសំរាប់ធ្វើសកម្មភាព ដើម្បីសំរេចគោលបំណង

យុទ្ធសាស្ត្របង្ហាញពីវិធី ដើម្បីសំរេចគោលបំណង ។ ក្នុងពេលកំនត់យុទ្ធសាស្ត្រ គេត្រូវពិចារណាថា :

⇨ តើអាចសំរេចគោលបំណង ដោយរបៀបណានៅក្នុងកំឡុងពេលជាក់លាក់មួយ ?

⇨ តើបច្ចុប្បន្នអង្គភាពដែលនឹងអនុវត្តផែនការគ្រប់គ្រងធនធាន មានសមត្ថភាពកំរិតណា ?

**សំនួរណែនាំសំរាប់កំនត់សកម្មភាពរួមមាន:**

⇨ តើយុទ្ធសាស្ត្រនឹងត្រូវអនុវត្តបានតាមរយៈសកម្មភាពផ្សេងៗឬ ?

⇨ តើយើងមានជំនាញ ចំណេះដឹង និងធនធានគ្រប់គ្រាន់សំរាប់អនុវត្តសកម្មភាពទាំងនោះដែរឬទេ ?

⇨ តើយើងបានដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ស្ត្រី និងបុរសទៅក្នុងសកម្មភាព ទាំងនោះដែរឬទេ ?

⇨ តើសហគមន៍ឯកភាពចំពោះសកម្មភាពទាំងនោះដែរឬទេ ?

⇨ តើសកម្មភាពទាំងនោះ អាចបំពេញបាននៅក្នុងកំឡុងពេលដែលបានកំណត់ដែរឬទេ ?

⇨ តើសកម្មភាពទាំងនោះ ទាក់ទងនឹងស្ថានភាពបច្ចុប្បន្ននៅក្នុងសហគមន៍ដែរឬទេ ?

⇨ តើការអនុវត្តសកម្មភាពទាំងនោះ ផ្តល់ផលចំណេញដែរឬទេ ?

សកម្មភាពគឺជាមធ្យោបាយក្នុងការអនុវត្តន៍យុទ្ធសាស្ត្រដើម្បីគោលបំណង ។

ឧទាហរណ៍: ការកំនត់គោលបំណង / យុទ្ធសាស្ត្រ / សកម្មភាព ក្នុងខេត្តកោះកុង

| | |
|---|---|
| គោលបំណង | បញ្ឈប់ការប្រើប្រាស់ឧបករណ៍ឈិបយន្តនៅជ្រោយប្រស់ ។ |
| យុទ្ធសាស្ត្រ | រៀបចំបង្កើតសហគមន៍នេសាទនៅក្នុងតំបន់ ។ |
| សកម្មភាព | • ធ្វើវិធីវិភាគជនបទដោយមានការចូលរួម (PRA) ។<br>• ជ្រើសរើសប្រជាពលរដ្ឋដែលចង់ចូលរួម ។<br>• អញ្ជើញប្រជាពលរដ្ឋទៅទស្សនាសហគមន៍ផ្សេងទៀត ។<br>• រៀបចំបទបញ្ជាសំរាប់សហគមន៍ និងផែនការការងារ ។<br>• ស្នើឱ្យអាជ្ញាធរគាំទ្របទបញ្ជាសហគមន៍ ។<br>• បើកសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលអំពីបទបញ្ជាសហគមន៍ ។<br>• ពង្រឹង និងពង្រីកសមាជិកភាពសហគមន៍ ។ |

## រៀបចំកត្តាចង្អុលបង្ហាញ និងការធ្វើផែនការសកម្មភាព

កត្តាចង្អុលបង្ហាញ ប្រើប្រាស់ដើម្បីតាមដានដំនើរការការងាររបស់យើង ។ កត្តាចង្អុលបង្ហាញនឹងនាំផ្លូវយើងឱ្យដឹងថាត្រូវធ្វើអ្វី នៅពេលបន្ទាប់ ។ យើងមានកត្តាចង្អុលបង្ហាញបីបែប:

> **កត្តាចង្អុលបង្ហាញត្រូវតែ:**
> ជាក់លាក់
> ដោយផ្ទាល់
> អាចសំរេចបាន
> អាចវាស់ ឬថ្លឹងថ្លែងបាន

⇨ កត្តាចង្អុលបង្ហាញពីបរិមាណសំដៅលើចំនួនជាលេខ ឧទា. ភាគរយនៃកំណើនប្រាក់ចំណូល

⇨ កត្តាចង្អុលបង្ហាញពីគុណភាពសំដៅលើសេចក្តីអធិប្បាយអំពីស្ថានភាព ឧទា. រូបភាពនៃការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពនានា

⇨ កត្តាចង្អុលបង្ហាញពីឥរិយាបទសំដៅលើអ្វី ដែលបង្ហាញអំពីការប្រែប្រួលអាកប្បកិរិយា ឧទា. ឥរិយាបទរបស់អ្នកនេសាទប្រឆាំងនឹងការនេសាទខុសច្បាប់ ។

ក្រោយពេលបានរៀបចំ និងឯកភាពលើកត្តាចង្អុលបង្ហាញរួចហើយ ជំហានចុងក្រោយគឺការធ្វើផែនការសកម្មភាព ។ ផែនការសកម្មភាពត្រូវបង្ហាញពីសកម្មភាពនានាដែលត្រូវអនុវត្ត ដើម្បីសំរេចគោលដៅ ។ សកម្មភាពត្រូវតែជាក់លាក់ និងគ្រប់គ្រាន់ដើម្បីសំរួលដល់ការគ្រប់គ្រង ។ ផែនការក៏ត្រូវបង្ហាញផងដែរអំពីតំរូវការថវិកា និងធនធានមនុស្សដែលត្រូវអនុវត្តកិច្ចការ ។

**ឧទាហរណ៍: ផែនការសកម្មភាពមួយ**

**គោលបំណង :** កាត់បន្ថយការប្រើប្រាស់ឈើបយន្តដោយខុសច្បាប់នៅតំបន់ក្បែរភូមិកោះកាង

**រយៈពេលអនុវត្ត ( ខែ និង ឆ្នាំ):** ខែ កក្កដា - ធ្នូ ឆ្នាំ ២០០១

**រៀបចំដោយ:** គណៈកម្មការភូមិកោះកាង

| សកម្មភាព | រយៈពេល អនុវត្ត | តំរូវការថវិកា | អ្នកអនុវត្ត | កត្តាចង្អុលបង្ហាញ |
|---|---|---|---|---|
| កែសំរួលច្បាប់បច្ចុប្បន្ន ទាក់ទងនឹងការនេសាទ ដោយឈើបយន្ត ពោលគឺ ច្បាប់នេសាទ | ខែកក្កដា ២០០១ | (៥០០០រៀល) ថ្លៃទូកទៅខេត្តកោះកុង ទៅមកដើម្បីធ្វើការជាមួយគំរោង ការចូលរួមគ្រប់គ្រងធនធានព្រៃកោងកាង ឬស្ថាប័នពាក់ពន្ធ័ | គណៈកម្មការ | ច្បាប់ផលផលត្រូវបានកែសំរួល |
| ស្រាវជ្រាវអំពីផលប៉ះពាល់បរិស្ថាន បណ្តាលពីការប្រើ ឧបករណ៍ឈើបយន្ត | ខែកក្កដា ២០០១ | ??? | គណៈកម្មការភូមិ និងស្ថាប័នជំនាញ ។ | ចងក្រងឯកសារបង្ហាញពីផលវិជ្ជមាន និងអវិជ្ជមាន នៃការនេសាទដោយឈើបយន្ត ។ |
| ផ្សព្វផ្សាយរបាយការណ៍ | សីហា ២០០១ | (ថតចំលងឯកសារ) | គណៈកម្មការភូមិ | ចែកចាយរបាយការណ៍ទៅស្ថាប័នរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងភូមិ ។ |
| | ខែកញ្ញា | (៥០០០រៀល) ប្រាក់ | គណៈកម្មការភូមិ | ល្បាត១២ដងក្នុងមួយខែ ការ |

| | | | | |
|---|---|---|---|---|
| សកម្មភាពល្បាត | ២០០១ - ខែធ្នូ ២០០១ | សំរាប់ទិញសាំង ៣ថ្ងៃ/សប្តាហ៍ ពោលគឺ ៤៥លីត្រ/សប្តាហ៍ ។ ក្រដាស់ និងប៊ិចសំរាប់កត់ត្រាសកម្មភាពល្បាត ។ | សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញ ។ | នេសាទដោយឈិបយន្តថយចុះ ។ |
| កសាងប៉ុស្តិ៍ល្បាត | ១០ថ្ងៃសំរាប់សង់ធ្វើនៅក្រោយរដូវភ្លៀង ។ | ៩.៥០០ បាត (សំរាប់ទិញ សំភារៈ) ។ | គណៈកម្មការភូមិ និងសហគមន៍មូលដ្ឋាន ។ | សហគមន៍ប្រើប្រាស់ប៉ុស្តិ៍សំរាប់ល្បាត ។ |

## ផ្នែកទី៩: ការធ្វើសំយោគលទ្ធផលវគ្គបណ្ដុះបណ្ដាល

### តើការសំរបសំរួល មានន័យដូចម្ដេច ?

ការសំរបសំរួលមានន័យថា "ធ្វើអ្វីមួយឱ្យងាយស្រួល" ។ ហេតុនេះ អ្នកសំរបសំរួលគឺជាបុគ្គលដែលធ្វើអ្វីឱ្យមានភាពងាយស្រួលសំរាប់បុគ្គលិក ឬ ក្រុមណាមួយ ក្នុងករណីសិក្សារបស់យើងគឺសហគមន៍ ។

ការគ្រប់គ្រងសហគមន៍

> **យុទ្ធសាស្ត្រជាគន្លឹះក្នុងការគ្រប់គ្រង សហគមន៍នេសាទ គឺការធ្វើផែនការអំពីការចូលរួមគ្រប់គ្រងធនធាន**

នេសាទ គឺជាការរៀបចំឱ្យមាន **សហគមន៍រឹងមាំ** ដែលចេះធ្វើផែនការគ្រប់គ្រងធនធាន ដែលអាចកំនត់បានទូវបញ្ហា និងដំណោះស្រាយជាអាទិភាពដែលធ្វើការជាមួយរដ្ឋាភិបាល និងលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រី និងបុរសក្នុងការគ្រប់គ្រង



ធនធានធម្មជាតិ ។

> ក្នុងនាមជាអ្នកសំរបសំរួល យើងមិនត្រូវធ្វើការផ្លាស់ប្តូរអ្វីៗសំរាប់សហគមន៍ទេ ។ កិច្ចការរបស់យើងគឺដើម្បីធ្វើឱ្យការងារមានភាពងាយស្រួលសំរាប់សហគមន៍ ពោលគឺជួយធ្វើឱ្យសហគមន៍រឹងមាំ ។

មធ្យោបាយចាំបាច់សំរាប់ធ្វើការងារនេះរួមមានៈ

- ការកំណត់ និងវិភាគបញ្ហា
- ការវិភាគភាគីពាក់ព័ន្ធ
- ការរៀបចំគោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព
- ការរៀបចំកត្តាចង្អុលបង្ហាញ និង
- ការធ្វើផែនការសកម្មភាព

ក្នុងនាមជាអ្នកសំរបសំរួល ការគ្រប់គ្រង សហគមន៍នេសាទ យើងគួរ តែសួរសំណួរដូចខាងក្រោមៈ

- តើអ្នកណាខ្លះចូលរួម ? តើ អ្នកណាខ្លះមិនចូលរួម ?
- តើពួកគេចូលរួមដោយរបៀបណា ?
- តើយើងចូលរួមសហការអ្វីខ្លះជាមួយសហគមន៍ ?
- តើសហគមន៍សហការអ្វីខ្លះជាមួយយើង ?

# ល្បែង និងលំហាត់ផ្សេងៗ

## អំពីការណែនាំរបស់សិក្ខាកាម

ខ្ញុំជា...

សិក្ខាកាមទាំងឡាយត្រូវបានណែនាំឱ្យឈរបន្តគ្នាជារង្វង់ ។ រាល់សិក្ខាកាមទាំងអស់ធ្វើការណែនាំអំពីខ្លួនឯងទៅកាន់អ្នកដ៏ទៃទៀត ដោយប្រាប់ឈ្មោះ និងសំដែងជាសកម្មភាពខ្លះៗ ឬក៏ឈរនៅមួយកន្លែង ។ ឧទាហរណ៍: ម្នាក់ៗអាចណែនាំអំពីខ្លួនឯងផង និងបញ្ចេញជាកាយវិការកាច់ចង្កេះពីកន្លែងមួយទៅកន្លែងមួយផង ។

អ្នកសំរបសំរួលជាអ្នកជ្រើសតាំងសិក្ខាកាមដែលត្រូវឡើងណែនាំមុនគេ ។ បន្ទាប់ពីសិក្ខាកាមទីមួយបានណែនាំខ្លួនឯង និងសំដែងនូវកាយវិការរួចហើយ អ្នកដែលនៅខាងស្តាំដៃសិក្ខាកាមទីមួយនោះ ត្រូវឡើងណែនាំខ្លួនឯងបន្ត សំដែងជាកាយវិការ និងប្រកាសឈ្មោះអ្នកឡើងសំដែងមុន ព្រមទាំងធ្វើកាយវិការត្រាប់តាមទៀតផង ។ សិក្ខាកាមត្រូវឡើងសំដែងបែបនេះរហូតបានគ្រប់គ្នា ។

### បំលាស់ប្តូរទី ១

ជំនួសនឹងការសំដែងជាកាយវិការ សិក្ខាកាមអាចណែនាំខ្លួនឯងដោយប្រើគុណនាមមួយពាក្យភ្ជាប់ជាមួយឈ្មោះរបស់ខ្លួន ។ ឧទាហរណ៍: ខ្ញុំឈ្មោះ " សុខរីករាយ " ឬក៏ខ្ញុំឈ្មោះ " គ្រឹមចំឡែក " ។ សិក្ខាកាមអាចដាក់គុណនាមច្រើនជាងមួយបាន ឧទាហរណ៍: "ខ្ញុំឈ្មោះកល្យាណទាក់ទាញចិត្តយ៉ាងរំភើប" ។

### បំលាស់ប្តូរទី ២

ជំនួសនឹងការសំដែងជាកាយវិការ សិក្ខាកាមអាចបញ្ចេញជាសំលេង ។

## ការផ្លាស់ប្តូរថុំគ្រាប់ក្នុងពេលធ្វើការណែនាំ

ដើម្បីលេងល្បែងនេះ អ្នកសំរបសំរួលត្រូវផ្តល់គ្រាប់រុក្ខជាតិ គ្រាប់គ្រួស ឬដុំថ្មតូចៗ ឱ្យទៅសិក្ខាកាម ។ បើសិនជាសិក្ខាកាមទាំងអស់មានគ្នា ២០នាក់ ដូច្នេះសិក្ខាកាមម្នាក់ៗ ត្រូវទទួលយកដុំគ្រាប់ចំនួន ២០គ្រាប់ ។ ចំនួនមនុស្សចូលរួមលេងល្បែងនេះ ត្រូវឱ្យមាន ត្រឹមតែ ១០-២០នាក់ ប៉ុណ្ណោះជាការប្រសើរ ពីព្រោះបើមានមនុស្សច្រើនជាងនេះ ល្បែងនឹង ត្រូវបន្ទាយពេលយូរ ។ បន្ទាប់ពីបានផ្តល់ដុំគ្រាប់ដល់សិក្ខាកាមរួចហើយ អ្នកសំរបសំរួលត្រូវ សំណូមពរទៅសិក្ខាកាមទាំងអស់ឱ្យដាក់ដុំគ្រាប់ទាំងអស់ចូលទៅក្នុងហោប៉ៅមួយ នឹងត្រូវឱ្យ មានហោប៉ៅមួយទៀតទំនេរ ។ បើសិក្ខាកាមណាគ្មានហោប៉ៅសំរាប់ដាក់ដុំគ្រាប់នេះទេ អ្នក សំរបសំរួលត្រូវផ្តល់កូនប្រអប់តូចៗជូន ។ បន្ទាប់មក អនុញ្ញាតិឱ្យសិក្ខាកាមទាំងអស់ដើរ ធ្វើការណែនាំខ្លួនឯងទៅកាន់អ្នកដទៃនៅក្នុងបន្ទប់ ។ អ្នកសំរបសំរួលត្រូវកំណត់ពេលសំរាប់ លេងល្បែងនេះ ។ ក្នុងពេលធ្វើការណែនាំ សិក្ខាកាមទាំងពីរនាក់ដែលណែនាំគ្នានោះត្រូវផ្តល់ និងទទួលយកដុំគ្រាប់ ១គ្រាប់ពីគ្នាទៅវិញទៅមក ។ ដុំគ្រាប់ដែលទទួលបានពីអ្នកដទៃ ត្រូវ ដាក់ចូលទៅក្នុងហោប៉ៅ ឬប្រអប់ដែលទំនេរ ។ នៅចុងបញ្ចប់ សិក្ខាកាមម្នាក់ៗត្រូវមាន ដុំគ្រាប់ ១គ្រាប់គត់នៅក្នុងហោប៉ៅចាស់ ហើយហោប៉ៅថ្មីត្រូវមានចំនួនស្មើនឹងចំនួនសិក្ខាម ទាំងអស់ដកមួយចេញ ។

## ការគូររូបអ្នកជិតខាង

ជាដំបូង ស្នើឱ្យសិក្ខាកាមទាំងអស់អង្គុយជារង្វង់ ។ សំភារៈសំរាប់គូររូប ដូចជាក្រដាស់ ខ្មៅដៃ ... ត្រូវផ្តល់ជូនដល់សិក្ខាកាមគ្រប់ៗគ្នា ។ បន្ទាប់មក អ្នកសំរបសំរួលសំណូមពរ ទៅកាន់សិក្ខាកាមនីមួយៗ ឱ្យសិក្សានិងពិនិត្យអ្នកដែលស្ថិតនៅខាងស្តាំដៃខ្លួន ដោយចាប់ អារម្មណ៍លើរូបរាង សណ្ឋានទៃសំលៀកបំពាក់ និងចរិកលក្ខណៈដែលអាចកត់សំគាល់បាន ។ អ្នកសំរបសំរួលត្រូវប្រាប់សិក្ខាកាមទាំងអស់ សរសេរឈ្មោះអ្នកដែលខ្លួនគូរចូលផង ។ បន្ទាប់

មកទៀត សិក្ខាកាមម្នាក់ៗត្រូវចាប់ផ្តើមគូររូបអ្នកជិតខាងរបស់ខ្លួននូវអ្វីដែលអាចកត់សំគាល់ និងអាចឡើងធ្វើបទបង្ហាញបាន ។ នៅពេលដែលការគូររូបបានបញ្ចប់ សិក្ខាកាមម្នាក់ៗ អនុញ្ញាតិឱ្យឡើងធ្វើបទបង្ហាញអំពីកិច្ចការរបស់ខ្លួនម្នាក់ម្តងៗ ទៅកាន់សិក្ខាកាមទាំងអស់ ។

## ការណែនាំខ្លួនឯងតាមរយៈរូបសញ្ញា

អ្នកសំរបសំរួលត្រូវស្នើសុំឱ្យសិក្ខាកាមដើររើសវត្ថុនៅក្នុងបន្ទប់ ឬក្រៅបន្ទប់ដើម្បីធ្វើជារូបតំណាងខ្លួនគាត់ ។ សិក្ខាកាមត្រូវបានផ្តល់ជូនរយៈពេលតែ ៥-១០នាទី ដើម្បីដើររើសវត្ថុ ។ បន្ទាប់មក សំណូមពរពួកគាត់ឱ្យអង្គុយជារង្វង់ ហើយពន្យល់ទៅកាន់អ្នកដទៃអំពីមូលហេតុដែលវត្ថុគាត់រើសនោះជាតំណាងរូបគាត់ ។ លំហាត់នេះមានសារៈសំខាន់ដើម្បីលើកទឹកចិត្តដល់សិក្ខាកាម ក្នុងការបើកចំហរ និងផ្លាស់ប្តូរអារម្មណ៍របស់គាត់ នៅពេលចាប់ផ្តើមសិក្សា ។

# ការបង្កើនភាពស្និទ្ធស្នាល និងការធ្វើឱ្យមានភាពរីករាយ

## សួរស្តី

អ្នកសំរបសំរួលស្នើឱ្យសិក្ខាកាមឈរបន្តគ្នាជារង្វង់ ។ បន្ទាប់មកត្រូវពន្យល់ទៅកាន់ពួកគាត់ថា សិក្ខាកាមម្នាក់ៗត្រូវប្តូរវេនគ្នានិយាយពាក្យ "សួរស្តី" ព្រមទាំងបញ្ចេញនូវកាយវិការ ឬធ្វើមុខជាសញ្ញា ។ ឧទាហរណ៍ៈ អ្នកសំរបសំរួលចាប់ផ្តើមនិយាយថា សួរស្តី ដោយគ្រវីដៃ ។ អ្នកបន្ទាប់ត្រូវនិយាយថា សួរស្តី ហើយធ្វើឱ្យដូចអ្វីដែលអ្នកសំរបសំរួលបានធ្វើ ។ សិក្ខាកាមទាំងអស់ត្រូវធ្វើម្នាក់ម្តងៗរហូតបានគ្រប់គ្នា ។

## មេ្ទសហើរ

ជាដំបូង អនុញ្ញាតិឱ្យសិក្ខាកាមទាំងអស់អង្គុយជារង្វង់ ។ បន្ទាប់មក អ្នកសំរបសំរួលឈរនៅចំកណ្តាលនៃរង្វង់ដោយកាន់វត្ថុមួយ ឧទាហរណ៍ៈ កូនបាល់តូចមួយ ហើយប្រាប់ទៅសិក្ខាកាមទាំងអស់ថា នេះជា "មេ្ទសហើរ" សំរាប់ល្បែងរបស់យើង ។ បន្ទាប់មកទៀត អ្នកសំរបសំរួលប្រាប់ទៅសិក្ខាកាមឱ្យបិទភ្នែក ។ រួចហើយ អ្នកសំរបសំរួលហុចបាល់ព្រាវទៅឱ្យសិក្ខាមម្នាក់ និងប្រាប់សិក្ខកាមនោះបន្តហុចបាល់ទៅឱ្យអ្នកខាងស្តាំដៃ ដោយនិយាយថា "ហើរ" ។ សិក្ខាកាមនីមួយៗបន្តហុចបាល់ពីម្នាក់ទៅម្នាក់ទៀតដោយនិយាយថា "ហើរ" រហូតដល់ឮសំលេងពីអ្នកសំរបសំរួលនិយាយថា "មេ្ទស" ទើបឈប់ ។ នៅពេលដែលឈប់ បើបាល់ស្ថិតនៅលើដៃសិក្ខាកាមណា សិក្ខាកាមនោះនឹងត្រូវដើរចេញពីក្រុម ។ ល្បែងត្រូវបានបន្តរហូតដល់សល់ម្នាក់ ហើយអ្នកដែលនៅសល់ចុងក្រោយនេះ គឺជា អ្នកឈ្នះ ។

## តុក្កតា

ល្បែងនេះត្រូវលេងនៅក្នុងបន្ទប់ដោយមានរបាំង ដូចជាតុ ឬកៅអី ។ ជាដំបូង អ្នកសំរបសំរួលស្នើសុំឱ្យសិក្ខាកាមឈររាយនៅក្នុងបន្ទប់ ដែលអាចឱ្យសិក្ខាកាមម្នាក់ៗមានកន្លែងគ្រប់គ្រាន់ដើម្បីធ្វើចលនាបាន ។ នៅពេលដែលសិក្ខាកាមទាំងឡាយមានកន្លែងគ្រប់គ្នាហើយ អ្នកសំរបសំរួលពន្យល់ថា ក្នុងល្បែងនេះ អ្នកទាំងអស់គ្នាគឺជាតុក្កតា ។ ដូច្នេះ សិក្ខាកាមទាំងឡាយត្រូវស្តាប់តាម និងធ្វើត្រាប់តាមកាយវិការដែលអ្នកសំរបសំរួលសំណូមឱ្យធ្វើ ។ ឧទាហរណ៍ខ្លះៗនៃកាយវិការតុក្កតាដូចជា :

- ចាប់ដៃមនុស្សដែលរវើរវាយ
- ធ្វើនេសាទក្នុងបឹងមួយ
- ដាំដើមកោងកាង
- ក្រាបលើកំរាល

- ធ្វើជាចង្វាក់រាំ

ក្រោយពេលដែលល្បែងបានបញ្ចប់ អ្នកសំរបសំរួលត្រូវសួរទៅកាន់សិក្ខាកាមអំពីអារម្មណ៍របស់ពួកគាត់ក្នុងការធ្វើកាយវិការផ្សេងៗនេះ ។

**ការធ្វើកាយវិការ**

ល្បែងនេះត្រូវការបន្ទប់ទូលាយ ។ ជាការចាប់ផ្តើម អ្នកសំរប់សំរួលស្នើសុំឱ្យសិក្ខាកាមទាំងអស់ឈរពង្រាយគ្នានៅក្នុងបន្ទប់ ដោយទុកចន្លោះដែលអាចធ្វើចលនាបាន ។ បន្ទាប់មកទៀត អ្នកសំរបសំរួលពន្យល់ថា សិក្ខាកាមទាំងអស់ត្រូវចូលរួមលេងល្បែងនេះ ដើម្បីបន្ធូរកាយ និងអារម្មណ៍ ។ ក្រោយមក អ្នកសំរបសំរួលស្រែកឡើងដើម្បីធ្វើកាយវិការគ្រាប់តាមអ្វីមួយ ឧទាហរណ៍ ធ្វើជាឆ្កែដែលគួរឱ្យស្រឡាញ់ ។ សិក្ខាកាមនីមួយៗ ត្រូវធ្វើគ្រាប់ឱ្យដូចរូបតំណាងនេះ ហើយនឹងត្រូវធ្វើក្នុងរយៈពេល ១០វិនាទី ។ បន្ទាប់ពីការសំដែងនេះ អ្នកសំរបសំរួលប្រាប់ឱ្យសំរាក ។ ការលេងល្បែងនេះ បន្តទៅតាមលំដាប់នៃកាយវិការផ្សេងៗដែលអ្នកសំរបសំរួលស្នើសុំឱ្យធ្វើ ។ នៅពេលដែលគ្រប់កាយវិការទាំងអស់ បានសំដែងដូចហើយ អ្នកសំរបសំរួល អនុញ្ញាតិឱ្យសិក្ខាកាមទាំងអស់សំរាក ហើយនឹងប្រាប់ឱ្យធ្វើឡើងវិញក្នុងរយៈពេល ២នាទី ។

ឧទាហរណ៍ខ្លះនៃរូបតំណាង :

- កូនក្មេងម្នាក់កំពុងលេង
- ម្តាយម្នាក់កំពុងមើលកូន
- អ្នកនេសាទម្នាក់កំពុងគប់គ្រាប់បែក
- ស្វាមួយកំពុងហក់លេង
- អ្នករាំរបាំបាឡេ

## ការធ្វើទឹកមុខ

ជាដំបូង អ្នកសំរបសំរួលប្រាប់ឱ្យសិក្ខាកាមទាំងអស់ពង្រាយគ្នានៅក្នុងបន្ទប់ ដើម្បីធ្វើទឹកមុខផ្សេងៗតាមការស្នើពីអ្នកសំរបសំរួល ។ ឧទាហរណ៍ អ្នកសំរបសំរួលស្នើសុំឱ្យធ្វើទឹកមុខខឹង ហេតុដូច្នេះសិក្ខាកាមទាំងអស់ត្រូវធ្វើទឹកមុខតាមការស្នើសុំនេះ ។ សិក្ខាកាមទាំងអស់ត្រូវបានស្នើសុំឱ្យបន្តធ្វើទឹកមុខបែបនេះ រហូតដល់អ្នកសំរបសំរួលប្រាប់ឱ្យធ្វើទឹកមុខផ្សេងមួយទៀត ។ សិក្ខាកាមទាំងអស់ត្រូវបានអនុញ្ញាតឱ្យឈប់ ហើយពិនិត្យមើលថា តើអ្នកណាមួយធ្វើទឹកមុខដូចជាងគេ ។ សិក្ខាកាមទាំងអស់មិនអនុញ្ញាតឱ្យសើច លុះត្រាតែអ្នកសំរបសំរួលប្រាប់ឱ្យសើច ។

ឧទាហរណ៍ ការធ្វើទឹកមុខផ្សេងៗ :

- អ្នកទាំងអស់គ្នាស្អប់ខ្ញុំ
- ខ្ញុំល្អជាងអ្នក
- ខ្ញុំជាមនុស្សច្រណែន
- ខ្ញុំស្រឡាញ់អ្នក
- ខ្ញុំចូលចិត្តអ្នក
- ខ្ញុំស្អប់អ្នក
- ខ្ញុំជាមនុស្សឯកោ
- ខ្ញុំរីករាយ

# ដំណោះស្រាយបញ្ហា

## គេចផុតពីបញ្ហាក្នុងចិត្ត

ជាដំបូង អ្នកសំរបសំរួលពន្យល់ថា "គេចផុតពីបញ្ហាក្នុងចិត្ត" មានន័យថា មនុស្សម្នាក់ត្រូវបានរំខានដោយអ្វីមួយ (ឧទាហរណ៍ : ខឹងនឹងអំពើរបស់មិត្តភក្តិម្នាក់) ហើយមនុស្សម្នាក់នោះចង់ដោះស្រាយបញ្ហានេះចេញដោយចំហរ ដោយសារកំហឹងរបស់គាត់គ្រាន់តែជាការចាប់ផ្តើម ។ លំហាត់នេះ ទាក់ទងផ្ទាល់ទៅនឹងក្រុមមនុស្សក្នុងសហគមន៍ដែលចង់បង្ហាញអំពីទុក្ខព្រួយរបស់ខ្លួន រឺបញ្ហាដែលមានទំនាស់ទៅនឹងក្រុមមនុស្សផ្សេងទៀត ។ លំហាត់នេះ ក៏បានផ្តល់នូវឱកាសមួយសំរាប់សហគមន៍ដើម្បីស្វែងរកមធ្យោបាយដោះស្រាយបញ្ហា ។

ជំហានបន្ទាប់ សំរាប់ឱ្យសិក្ខាកាមជ្រើសរើសថា តើខ្លួនស្ថិតនៅក្នុងក្រុមមនុស្សរបស់សហគមន៍ណា ហើយអ្នកសំរបសំរួលអាចសំរេចចិត្តថា តើត្រូវរៀបចំមនុស្សប៉ុន្មានក្រុម តែមិនត្រូវឱ្យលើសពីបួនក្រុម ។ ហើយសិក្ខាកាមអាចជ្រើសរើសជាក្រុមមនុស្សក្រៅសហគមន៍ ឧទាហរណ៍ : អ្នកនេសាទមកពីភូមិជិតខាង អ្នកបំរើការអង្គការក្រៅរដ្ឋាភិបាល ។ល។ នៅពេលដែលក្រុមមនុស្សត្រូវបានកំណត់ និងសិក្ខាកាមត្រូវជ្រើសរើសថាខ្លួនចូលរួមក្នុងក្រុមណាហើយនោះ អ្នកសំរបសំរួលត្រូវណែនាំសិក្ខាកាមឱ្យដាក់ខ្លួន ជជែកការពារក្រុមតទល់នឹងគូបដិបក្ស ។ ក្រោយពេលដែល សិក្ខាកាមរៀបចំក្រុមដោយខ្លួនឯងអស់រយៈពេល ៥នាទីរួចហើយ អ្នកសំរបសំរួលត្រូវអនុញ្ញាតិឱ្យក្រុមទាំងអស់ធ្វើការពិភាក្សាគ្នា ។ នៅពេលដែលការពិភាក្សាបានបញ្ចប់ អ្នកសំរបសំរួលត្រូវសុំឱ្យក្រុមទាំងឡាយកត់ត្រារកមធ្យោបាយដែលអាចដោះស្រាយបញ្ហាបាន ។ មានតែវិធីមួយប៉ុណ្ណោះ ដើម្បីកំណត់បានដំណោះស្រាយ : គឺកិច្ចព្រមព្រៀង និងទំនាក់ទំនងដែលព្រមទទួលដោយអ្នកដែលស្នើសុំឱ្យមានដំណោះស្រាយនេះ ។ នៅពេលដែលអ្នកទាំងអស់គ្នារៀបចំរួចស្រេចហើយ ក្រុមនីមួយៗត្រូវឡើងធ្វើ

បទបង្ហាញ ដោយបង្ហាញពីគំនិតដែលបានជជែកគ្នា និងដំណោះស្រាយដែលបានស្នើសុំ ។ នៅចុងបញ្ចប់ អ្នកសំរបសំរួលត្រូវរៀបចំ និងធ្វើសេចក្តីសង្ខេបនូវចំណុចជាគន្លឹះដែលលើកឡើងក្នុងលំហាត់នេះ ។

## ការចូលរួម និងការសហការ

### ការបង្កើតជាសត្វមួយ

ជាដំបូង អ្នកសំរបសំរួលត្រូវបែងចែកជាក្រុមតូចៗដែលមានចំនួនមនុស្ស ៤-៥នាក់ ។ ក្រុមតូចៗទាំងនោះ ស្ថិតនៅកន្លែងដែលពួកគេធ្វើការផ្សេងៗគ្នា ។ បន្ទាប់មក អ្នកសំរបសំរួលប្រាប់ទៅក្រុមនីមួយៗឱ្យរៀបចំជាសត្វ ដោយចេញពីខ្លួនរបស់ពួកគេ ដូចជា អ្នកខ្លះដើរតួរជាក្បាលសត្វ អ្នកខ្លះជាដៃ ជាបាតដៃ ជាជើង ជាបាតជើង និងជាកន្ទុយ ។ សមាជិកក្រុមម្នាក់អាចដើរតួរច្រើនផ្នែកបាន ។ ឧទាហរណ៍ : មនុស្សម្នាក់អាចធ្វើជាក្បាលសត្វផង និងខ្លួនសត្វផង ។ មានតែការបង្ហាញសំខាន់មួយប៉ុណ្ណោះ គឺជាសត្វដែលអាចដើរ ឬមានចលនាផ្សេងៗក្នុងរបៀបផ្សេងគ្នា ។ សិក្ខាកាមទាំងអស់ត្រូវបានអនុញ្ញាតិពេល ១០នាទី ដើម្បីរៀបចំយុទ្ធវិធី និងការបង្កើតជាសត្វ ។ អ្នកសំរបសំរួលលើកទឹកចិត្តដល់សិក្ខាកាមទាំងអស់ ឱ្យបង្កើតជាសត្វ និងដាក់ឈ្មោះរបស់សត្វនោះផងបើសិនជាអាច ។ នៅពេលដែលសិក្ខាកាមទាំងអស់រៀបចំរួចហើយ ក្រុមនីមួយៗត្រូវសំដែងជាសត្វ បង្ហាញក្រុមទាំងអស់ ។ បន្ទាប់ពីល្បែងនេះចប់ អ្នកសំរបសំរួលអាចអនុវត្តនូវបទពិសោធន៍ ដោយសួរទៅកាន់សិក្ខាកាមជាសំនួរមួយចំនួនដែលទាក់ទងនឹងការចូលរួម និង សហការ ។










THĂNG LONG